# សារៈសំខាន់នៃអនុសញ្ញាស៊ីដ
# (CEDAW)

## តើអនុសញ្ញានេះអនុវត្តដូចម្តេចក្នុងបរិបទកម្ពុជា ?



**ទស្សនវិស័យ  សម្រាប់  សហស្សវត្សរ៍ថ្មី**

"មនុស្សគ្រប់រូបកើតមកមានសេរីភាព និងសមភាពខាងសិទ្ធិ និងសេចក្តីថ្លៃថ្នូរដូចៗគ្នា"

*សេចក្តីប្រកាសជាសាកលស្តីអំពីសិទ្ធិមនុស្ស*

កូនសៀវភៅនេះ ត្រូវបានសរសេរឡើងក្នុងការជួយផ្តល់នូវគំនិតសំខាន់ៗ ដើម្បីបង្កើនការយល់ដឹងអំពីអនុសញ្ញារបស់អង្គការសហប្រជាជាតិ ស្តីអំពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ ។ យើងមានក្តីសង្ឃឹមថាសៀវភៅនេះនឹងជួយជំរុញការឈានទៅមុខ ជាក់ស្តែងក្នុងវិស័យគុណភាពនៃជីវភាពរស់នៅរបស់ស្ត្រីខ្មែរ ។ យើងមានគោលបំណងបង្កើនការភ្ញាក់រលឹកអំពីសិទ្ធិទាំងឡាយដែលស្ត្រីគ្រប់រូបមានសិទ្ធិទទួលបាន អនុលោមទៅតាមអនុសញ្ញាស៊ីដ ។

យើងសង្ឃឹមថាកូនសៀវភៅនេះនិងក្លាយជាធនធានមួយសម្រាប់មន្ត្រីរដ្ឋាភិបាល និងអ្នករ៉ាប់រងភារកិច្ចដទៃទៀត ភ្នាក់ងារតុលាការ ភ្នាក់ងារអនុវត្តច្បាប់ អង្គការមិនមែនរដ្ឋាភិបាល និងអ្នកតំណាងសិក្ខាវិទូ អ្នកមានវិជ្ជាជីវៈផ្នែកអប់រំនិងសិក្សាធិការព្រមទាំងសិស្សនិស្សិតទាំងឡាយ ។

ការបោះពុម្ពផ្សាយនេះជាកម្មវិធីរបស់ UNIFEM CEDAW Southeast Asian Program ។

ទស្សនៈទាំងអស់ក្នុងកូនសៀវភៅនេះគឺជាទស្សនៈរបស់អ្នករៀបរៀងផ្ទាល់ ហើយមិនមែនជាទស្សនៈរបស់ UNIFEM អង្គការសហប្រជាជាតិ ឬអង្គការសាខាណាមួយឡើយ ។

**រៀបរៀង និងកែសំរួលដោយ**

សាន់ឌី ហ្វីនហ្សិក ណាកាហ្គាវ៉ា កាស៊ូមី និង វ៉ារី យីះ

រចនា/គំនូរព្រាងដោយ
អាំ រស្មី

**បោះពុម្ពលើកទី ១ ចំនួន ២០០០ ក្បាល**
**ខែកក្កដា ឆ្នាំ ២០០៧ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា**

**UNIFEM** ជាមូលនិធិសម្រាប់ស្ត្រីនៅអង្គការសហប្រជាជាតិ ។ UNIFEM ផ្តល់ជំនួយបច្ចេកទេស និងហិរញ្ញវត្ថុ ដល់កម្មវិធី និងយុទ្ធសាស្ត្រទាំងឡាយដែលជួយលើកស្ទួយសិទ្ធិមនុស្ស និងការចូលរួមរបស់ស្ត្រីក្នុងវិស័យនយោបាយ និងសន្តិសុខផ្នែក សេដ្ឋកិច្ចរបស់ស្ត្រី ។ UNIFEM ធ្វើការជាដៃគូជាមួយអង្គភាពផ្សេងទៀត នៃអង្គការ សហប្រជាជាតិ ជាមួយរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល (NGOs) ព្រមទាំងបណ្តាញទាំងឡាយ ដើម្បីលើកកម្ពស់សមភាពយេនឌ័រ ។ UNIFEM ភ្ជាប់បញ្ហា និងការយកចិត្តទុកដាក់ទាំងឡាយរបស់ស្ត្រីទៅនឹង របៀបវារៈថ្នាក់ជាតិ ថ្នាក់តំបន់ និងថ្នាក់សាកល ដោយឧបត្ថម្ភសហការ និងផ្តល់ជំនាញបច្ចេកទេសផ្នែកបញ្ជ្រាបយេនឌ័រ និងយុទ្ធសាស្ត្រដើម្បីបង្អាចស្ត្រី ។ ការិយាល័យ UNIFEM នៅប្រទេសកម្ពុជាផ្តល់ការគាំទ្រដល់គម្រោងមួយចំនួន ទាក់ទងនឹងស៊ីដ និងឧបករណ៍-ឯកសារហ្វឹកហាត់ផ្នែក CMDG ក្រោមជំនួយហិរញ្ញវត្ថុរបស់ ស៊ីដា ។

**សីលការ** ជាអង្គការក្នុងស្រុកមួយ ដែលមិនមាននិន្នាការនយោបាយ ឬសាសនាណាមួយឡើយ ហើយបានចុះឈ្មោះជាមួយក្រសួងមហាផ្ទៃ នៃរាជរដ្ឋាភិបាលកម្ពុជា ក្នុងខែមករាឆ្នាំ១៩៩៧ ។ បេសកម្មរបស់សីលការ គឺសម្របសម្រួលការអប់រំ ការអភិវឌ្ឍប្រជាជនកម្ពុជាដើម្បីពង្រឹងអង្គការ ស្ថាប័នរបស់គេ ដោយធ្វើការជាមួយបុគ្គលអង្គការ និងស្ថាប័ន ដែលយកចិត្តទុកដាក់យ៉ាងសកម្មក្នុងកិច្ចការកសាងសមត្ថភាពកម្ពុជា ។ សីលការ បានរួមចំណែកក្នុងការអភិវឌ្ឍ និងអនុវត្តគម្រោងនានា ដែលបង្កើនទៅរក តម្លាភាព និងគណនេយ្យភាព នៅក្នុងកិច្ចប្រឹងប្រែង ដើម្បីជំរុញការរីកចម្រើនក្នុងវិស័យ រៀបចំអង្គការ និងស្ថាប័ន ។ ក្រោមទស្សនប្បញ្ញត្តិមួយដែលឃើញប្រទេសកម្ពុជាប្រកប ដោយសន្តិភាព សីលការបានប្តូរផ្តាច់ជួយ ឱ្យមានការផ្លាស់ប្តូរសង្គមប្រកបដោយ ការស្ថាបនាដែលអាចដោះស្រាយបាន ដោយមានប្រសិទ្ធភាពនូវសេចក្តីត្រូវការរួម របស់សង្គមកម្ពុជាទាំងមូល ដើម្បីផ្តល់នូវសន្តិភាព ការជានាគ្នា ដែលជាជំហានសំខាន់ដើម្បីបង្កើតនូវបរិយាកាស ជាអំណោយផលសម្រាប់ការអភិវឌ្ឍប្រកបដោយចេរភាព។

United Nations Development Fund for Women
UNIFEM

Supported by
Canadian International Development Agency
Agence canadienne de développement international

SILAKA

# សេចក្ដីថ្លែងអំណរគុណ

កូនសៀវភៅនេះ ជាផលសម្រេចពីវិភាគទានរបស់មនុស្សច្រើនរូប ដែលបានខិតខំប្រឹងប្រែងយ៉ាងខ្លាំង ដើម្បីសមាសភាគបញ្ចូលរបស់ខ្លួន ក្នុងការធ្វើឱ្យកូនសៀវភៅនេះតម្រូវទៅនិងស្ថានភាពសិទ្ធមនុស្ស និងការអភិវឌ្ឍន៍បច្ចុប្បន្នរបស់យើង ។

ខ្ញុំសូមអរគុណ ដល់អ្នកពិគ្រោះយោបល់ UNIFEM SEAP បីរូប មាន អ្នកស្រី **សាន់ឌី ហ្វីនហ៊្វក** អ្នកស្រី **ណាកាហ្គាវ៉ា កាស៊ូមី** និង អ្នកស្រី **ម៉ាឌុហ្គ មេរា** ចំពោះវិភាគទានផ្នែកច្បាប់ និងបច្ចេកទេសដទៃៗទៀតដល់កូនសៀវភៅនេះ ។ មាតិកាកូនសៀវភៅនេះបានដកស្រង់យ៉ាងច្រើន ចេញពីឯកសារផលិតដោយអ្នកស្រី ម៉ាឌុហ្គ មេរា និង Partners for Law in Development ដែលមានឈ្មោះថា “CEDAW: Restoring Rights to Women” ។ ខ្ញុំក៏សូមអរគុណ ដោយយើងអាចស្រង់ខ្លឹមសារខ្លះៗ ជាទុនសម្រាប់តាក់តែងឯកសារនេះឡើង បន្សុំអនុសញ្ញាស៊ីដ ទៅក្នុងបរិបទកម្ពុជា ។

ខ្ញុំសូមអរគុណ អ្នកស្រី **វ៉ារី ឃឹះ** អ្នកស្រី **សាន់ ផានិត** និងលោក **សាក់ សុធា** ចំពោះការស្រាវជ្រាវ និងប្រមូលផ្ដុំអត្ថបទទាំងឡាយ សម្រាប់កូនសៀវភៅនេះ ។ ខ្ញុំសូមអរគុណផងដែរចំពោះលោក**សីហ៍ វិសុទ្ធ** លោក**រិទ្ធ មុនីចន្ទោ** និងលោក**ឡេង សាមុត** ចំពោះសេចក្ដីព្យាយាមយ៉ាងស្វាហាប់ ក្នុងការបកប្រែអត្ថបទនានា ទៅវិញទៅមកច្រើនដងដើម្បីឆ្លុះបញ្ចាំង វិភាគទានទាំងឡាយដែលទទួល ។ សូមថ្លែងអំណរគុណចំពោះសមាជិកក្រុមប្រឹក្សាពិគ្រោះយោបល់ដែលមានបទពិសោធន៍ និងអញ្ជើញមកពី ក្រសួងកិច្ចការនារី ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ក្រសួងមហាផ្ទៃ ក្រសួងដែនដីនគរូបនីយកម្មនិងសំណង់ និងតំណាងអង្គការមិនមែនរដ្ឋាភិបាលជាតិនិងអន្តរជាតិ ដែលមានមកពី UNICEF, GTZ,

JICA UNFPA, World Education, CLEC, GAD/C, DISUF, NGOs Committee on CEDAW, PADV, Youth Star, RACHA ដែលបានផ្តល់ការសម្រេចចិត្តជាអាទិភាពត្រឹមត្រូវលើមាតិកា និងបញ្ហាអាទិភាពមួយភាគធំ ធ្វើឱ្យកូនសៀវភៅនេះ បានពាក់ព័ន្ធស៊ីជម្រៅទៅនឹងបរិបទកម្ពុជា ។

សំខាន់ជាងនេះទៅទៀត ខ្ញុំសូម អរគុណបណ្ឌិត **ឃីះ ជៀវ** ដែលបានស្ម័គ្រចិត្តធ្វើវិភាគទានពេលវេលា ជួយមើលការបកប្រែឡើងវិញនៅដំណាក់កាលចុងក្រោយ ដើម្បីរក្សាន័យដើមនៃវាក្យសព្ទនិងអត្ថបទអង់គ្លេស ក្នុងការបកប្រែនោះ និងផ្តល់នូវខ្លឹមសារខ្លះសម្រាប់កូនសៀវភៅនេះ ។ ការបកប្រែអត្ថបទនេះធ្វើឡើងដោយប្រើប្រាស់សន្ទានុក្រមនានាដែលមានស្រាប់ ។ សម្ភារៈយោងដែលត្រូវយកមកប្រើប្រាស់រួមមាន ៖ វចនានុក្រមខ្មែររបស់សម្តេច ជួន ណាត សទ្ទានុក្រមប្រជាសាស្ត្រ របស់សាកលវិទ្យាល័យភ្នំពេញ វចនានុក្រមច្បាប់របស់មូលនិធិអាស៊ី និង សទ្ទានុក្រមយេនឌ័រ របស់ក្រសួងកិច្ចការនារី និងវចនានុក្រមសេដ្ឋកិច្ចនិងសង្គមតាក់តែងដោយ **ហ៊ីង ថូរ៉ាក់ស៊ី** និង **ហ៊ាន សាហ៊ីប** ឆ្នាំ២០០៤។ ទោះជាមានការប្រឹងប្រែងច្រើនយ៉ាងណាក៏ខ្ញុំនៅជឿជាក់ថាមានកន្លែងខ្លះដែលអាចធ្វើឱ្យប្រសើរឡើងទៀត។ ដូច្នេះខ្ញុំសូមស្វាគមន៍នូវរាល់មតិយោបល់ ទាំងលើការជ្រើសរើសប្រើពាក្យក្នុងការបកប្រែវាក្យសព្ទគន្លឹះ ទាំងទៅក្នុងខ្លឹមសារ ដើម្បីយើងអាចកែលំអវាបាន នៅពេលបោះពុម្ពលើកក្រោយ ។

សូមឱ្យខ្មែរគ្រប់រូបទទួលបានសេចក្តីថ្លៃថ្នូរ និង ការគោរពគ្នាទៅវិញទៅមកដោយសន្តិភាព និង សេចក្តីរុងរឿង!

លោកស្រី **ឃីះ ធីដា**

នាយិកាប្រតិបត្តិ អង្គការសីលការ

# មាតិកា

ទំព័រ


សេចក្តីថ្លែងអំណរគុណ.....................................................................ii
ពាក្យកាត់ ...........................................................................................vi
ឯកសារយោង និងគេហទំព័រ ..........................................................vii
បុព្វកថា............................................................................................viii
១-តាមរយៈអនុសញ្ញាស៊ី-ដ : សិទ្ធិស្ត្រី គឺជាសិទ្ធិមនុស្ស ..................................... ១
- ភាពជាប់ទាក់ទិនគ្នារវាងសិទ្ធិមនុស្ស និងសិទ្ធិស្ត្រី ......................................... ១
- ទស្សនៈ (concept) ជាមូលដ្ឋានអំពីសិទ្ធិមនុស្ស ......................................... ៣
២-សេចក្តីផ្តើមអំពីអនុសញ្ញាស៊ី-ដ ..........................................................................៦
- ការយល់ដឹងអំពីក្របខណ្ឌការងារនៃអនុសញ្ញាស៊ី-ដ ......................................... ៧
- សមភាពសំខាន់........................................................................................៨
- ការរើសអើង/ការមិនរើសអើង.................................................................. ១២
- កាតព្វកិច្ចរដ្ឋភាគី..................................................................................... ១៩
៣-ក្របខណ្ឌការងារ និងច្បាប់ទាំងឡាយ ........................................................... ២៤
- ទំនាក់ទំនងរវាងសិទ្ធិស្ត្រី និងរដ្ឋធម្មនុញ្ញកម្ពុជា.............................................. ២៤
- បទប្បញ្ញត្តិទាំងឡាយសម្រាប់សិទ្ធិស្ត្រីនៅក្នុងច្បាប់នៃព្រះរាជាណាចក្រកម្ពុជា........ ៣៤
៤-យន្តការនៅពីក្រោយ របៀបវារៈ សមភាពយេនឌ័រប្រចាំសហស្សវត្សរ៍ ...............៤៥
- គោលដៅអភិវឌ្ឍន៍ប្រចាំសហស្សវត្សរ៍..........................................................៤៥
- គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា .......................................................៤៦
- វេទិកាប៉េកាំងសម្រាប់កិច្ចការ.................................................................. ៤៧

- ទំនាក់ទំនងរវាងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍សាកល គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា និងវេទិកាប៉េកាំងសម្រាប់កិច្ចការ.......................................៤៩
៥-យុទ្ធសាស្ត្រចតុកោណ.........................................................................៦៤
៦-អនុសញ្ញាស៊ីដ និងអ្នក ..................................................................... ៦៦

ឧបសម្ព័ន្ធ ៖

- សទ្ទានុក្រម ............................................................................... ៧០
- រូបភាព ប្រអប់១.១ កិច្ចសន្យាសង្គម និងឧបករណ៍................................. ៧
- រូបភាព ២.១ ផ្នែកសមភាពសំខាន់...................................................... ៩
- រូបភាព២.២ តើនៅពេលណាដែលភាពខុសគ្នា និង ប្រព្រឹត្តិកម្មខុសគ្នាខាងផ្នែកយេនឌ័រ បង្កឱ្យមានការរើសអើង តាមអនុសញ្ញាស៊ីដ ? .................. ១៥
- រូបភាព ២.៣ កាតព្វកិច្ចរបស់រដ្ឋភាគីចំពោះអនុសញ្ញាស៊ីដ .................... ២១
- តារាង ៣.១ តារាងប្រៀបធៀប រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងអនុសញ្ញា ស៊ីដ................................................................ ២៦

# ពាក្យកាត់
Abbreviation

| ពាក្យកាត់អង់គ្លេស | ពាក្យពេញជាខ្មែរ | ពាក្យពេញអង់គ្លេស |
|---|---|---|
| ASEAN | សមាគមនៃជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន) | Association of South-East Asia Nations |
| BPFA | ផែនការសកម្មភាពទីក្រុងប៉េកាំង | Beijing Platform for Action |
| CEDAW | អនុសញ្ញាស្តីពីការបំបាត់ចោលរាល់ទម្រង់ នៃការរើសអើងប្រឆាំងនារីភេទ (អនុសញ្ញាស៊ី-ដ) | Convention on the Elimination of All the Forms of Discrimination Against Women |
| CMDG | គោលដៅអភិវឌ្ឍន៍សហវត្សរ៍កម្ពុជា | Cambodian Millennium Development Goals |
| MDG | គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ពិភពលោក | Millennium Development Goals |
| NGO | អង្គការមិនមែនរដ្ឋាភិបាល - (អមរ) | Non-Government Organization |
| NPRS | យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ | National Poverty Reduction Strategy |
| NSDP | ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ | National Strategic Development Plan |
| RCG | រាជរដ្ឋាភិបាលកម្ពុជា | Royal Cambodian Government |
| SEDP | ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គម | Socio-Economic Development Plan |
| UDHR | សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស | Universal Declaration of Human Rights |
| UNIFEM | មូលនិធិអភិវឌ្ឍន៍អង្គការសហប្រជាជាតិសំរាប់ស្ត្រី | United Nations Development Fund for Women |
| UNIFEM SEAP | មូលនិធិអភិវឌ្ឍន៍អង្គការសហប្រជាជាតិសំរាប់ស្ត្រី - កម្មវិធីនៅអាស៊ីអាគ្នេយ៍ | United Nations Development Fund for Women - South East Asia Programme |

# ឯកសារយោង

Women and the Law, CLEC, 1998

Roberta Clark, Regional Program Director, UNIFEM, Caribbean, 2001

Madhu Mehra and the Partners for Law in Development materials as well as materials developed by IWRAW Asia Pacific.

*Pathway to Gender Equality, CEDAW, Beijing and the MDGs,* UNIFEM, GTZ and the German Federal Ministry for Economic Cooperation and Development

*Achieving the CMDGs 2005 Update,* Ministry of Planning, Royal Government of Cambodian, October 2005

*A Fair Share for Women, Cambodia Gender Assessment,* UNIFEM, World Bank, ADB, and DFID/UK and the MOWA, April 2004:

Original picture adopted from, ,*CEDAW, Restoring Rights to Women,* New Delhi, 2004

Royal Government of Cambodia, National Strategic Development Plan, 2006-2010

*Messengers of the CMDGs,* UNIFEM, UNDP and Japan Official Development Assistance

## LINKS

**Additional Information on CEDAW and Women's Rights**

United Nations, Division for the Advancement of Women (CEDAW)
http://www.un.org/womenwatch/daw/cedaw/
IWRAW Asia Pacific
A wealth of information on CEDAW application
http://iwraw-ap.org
Women's Human Rights Net
An expansive source of information and analysis on global women's rights issues
http://www.whrnet.org
Asia Pacific Forum on Women, Law and Development (APWLD)
http://www.apwld.org
Asian-Pacific Resource & Research Centre for Women (ARROW)
http://www.arrow.org.my
Committee for Asian Women (CAW)
http://www.cawinfo.org
UN Division of Advancement of Women
http://www.un.org/womenwatch/daw/
Women Watch
UN Internet Gateway on the advancement and empowerment of women
http://www.un.org/womenwatch
UNDP Gender in Development
http://www.undp.org/gender
United Nations High Commissioner for Human Rights
http://www.unhchr.ch/women/
UNESCAP Gender and Development Section
http://www.unescap.org/esid/GAD/index.asp

# បុព្វកថា

*សារៈសំខាន់ ដើម្បីឈានទៅដល់ការយល់ដឹងអំពីអនុសញ្ញាស៊ី-ដ វិធីក្នុងការយកមកអនុវត្ត នៅក្នុងបរិបទនៃប្រទេសកម្ពុជា ទស្សនវិស័យសំរាប់សហសវត្សរ៍ថ្មី* គឺជាការខិតខំប្រឹងប្រែងប្រកបដោយគំនិតឆ្នៃប្រឌិតរបស់អង្គការសិលការ ក្នុងការធ្វើអោយក្របខណ្ឌអនុសញ្ញាស៊ី-ដ (CEDAW) គោលការណ៍ ទស្សនៈ និងបទបញ្ញត្តិទាំងឡាយរបស់អនុសញ្ញានេះកាន់តែងាយយកមកអនុវត្តក្នុងបរិបទនៃប្រទេសកម្ពុជា ។ កូនសៀវភៅនេះគឺជាផ្នែកមួយនៃសម្ភារបង្រៀន ដែលរៀបចំដោយអង្គការសិលការសម្រាប់កម្មវិធីអនុសញ្ញាស៊ី-ដ អាស៊ីអាគ្នេយ៍ដោយមានការឧបត្ថម្ភមូលនិធិ ពីទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិនៃប្រទេសកាណាដា ឬហៅកាត់ថា ស៊ីដា / CIDA ។

កូនសៀវភៅនេះធ្វើឡើងបំណងលើកកម្ពស់ការយល់ដឹងអំពីអនុសញ្ញាស៊ី-ដ (CEDAW) និងគោលការទ៏សំខាន់ៗនៃសមភាពជាមូលដ្ឋាន ការមិនរើសអើង និងកាតព្វកិច្ចរបស់រដ្ឋ ចំពោះប្រជាពលរដ្ឋកម្ពុជា ។ អ្វីដែលប្លែកនៃសៀវភៅនេះ គឺវាមិនត្រឹមតែធ្វើអោយមានភាពស៊ីគ្នាច្រើនជាងមុនទៅនឹងប្រទេសកម្ពុជា តាមរយៈអនុសញ្ញាស៊ី-ដ (CEDAW) នេះទៅនឹងរដ្ឋធម្មនុញ្ញ នងនីតិកម្មរបស់ប្រទេសកម្ពុជាប៉ុណ្ណោះទេ ប៉ុន្តែសៀវភៅនេះមានបំណងផ្សាភ្ជាប់អនុសញ្ញាស៊ី-ដ (CEDAW) នេះទៅនឹងផែនការសកម្មភាពទីក្រុងប៉េកាំង (BPFA)និងគោលដៅអភិវឌ្ឍន៏សហស្សវត្សរ៏ផងដែរ (MDGs) ។

កូនសៀវភៅនេះមិនអាចលេចចេញជារូបរាងបានទេ ប្រសិនបើគ្មានភាពជាដៃគូដ៏រឹងមាំជាមួយនឹង ជំនាញការបច្ចេកទេស ទាំងមកពីក្នុងតំបន់អាស៊ី និងប្រជាពលរដ្ឋខ្មែរពីមជ្ឈដ្ឋានបណ្ឌិតសភា សង្គមស៊ីវិល និងរដ្ឋាភិបាលនោះ ។ ឧបសគ្គដែលយើងជួបប្រទេះក្នុង

ពេលកំពុងបង្កើតសៀវភៅនេះ គឺការដែលត្រូវត្រួតពិនិត្យមើលសំណៅជាភាសាអងគ្លេសជាមុនសិន ក្រោយមកទើបបកប្រែវាដើម្បីបានចេញជាសៀវភៅភាសាខ្មែរមួយក្បាល ។

យើងចាត់ទុកថាសៀវភៅនេះគឺជាធនធានសម្រាប់ការរៀនសូត្រមួយ ដែលបង្ហាញយ៉ាងច្បាស់ថា អនុសញ្ញាស៊ី-ដ (CEDAW)ផែនការសកម្មភាពទីក្រុងប៉េកាំង (BPFA) និងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ (MDGs)ទាំងអស់នេះ គឺជាឧបករណ៍ជួយដល់ការបណ្តុះបណ្តាលរបស់គ្រូបណ្តុះបណ្តាលរបស់កម្មវិធី UNIFEM CEDAW SEAP នៅក្នុងប្រទេសកម្ពុជា ។

យើងសូមកោតសសើរយ៉ាងខ្លាំងចំពោះការចូលរួមចំណែកដ៏មានតម្លៃរបស់អង្គការសីលការ ដើម្បីធ្វើអោយមានការយល់ដឹងកាន់តែប្រសើរឡើង អំពីការអនុវត្តអនុសញ្ញាស៊ី-ដ (CEDAW) នៅក្នុងប្រទេសកម្ពុជា ។

បណ្ឌិត ជិន ឪ កុនហា
នាយិកាកម្មវិធីប្រចាំតំបន់
អង្គការយូនីហ្វេមតំបន់អាស៊ីអាគ្នេយ៍

## តាមរយៈអនុសញ្ញាស៊ីដ :

១

# សិទ្ធិស្ត្រី គឺជាសិទ្ធិមនុស្ស

## ភាពជាប់ទាក់ទិនគ្នារវាងសិទ្ធិមនុស្ស និងសិទ្ធិស្ត្រី

ក្រោយពីសង្គ្រាមស៊ីវិលអស់ពីរទស្សវត្សរ៍មក ស្ត្រីនៅទូទាំងប្រទេសទទួលរងនូវសម្ពាធមួយយ៉ាងធ្ងន់ធ្ងរខុសពីធម្មតា ។ សង្គមកម្ពុជាមានទស្សនៈដោយឡែកអំពីសិទ្ធិអំណាច និងឋានៈ ដែលដាក់លក្ខខណ្ឌ ដល់ទំនាក់ទំនងយេនឌ័រ និងសង្គម ដែលកំពុង ឆ្លងកាត់ការផ្លាស់ប្តូរយ៉ាងខ្លាំង ។ នៅក្នុងសង្គមកម្ពុជា បច្ចុប្បន្ន ស្ត្រីបានកាន់មុខតំណែងបានប្រសើរ ហើយតែងមានការប្រឈមប្រជែង ជារឿយៗផងដែរ ។ គេរក្សាតុល្យភាព រវាងការទាមទារនៃទំនៀមទម្លាប់ប្រពៃណីកម្ពុជា និងការទាមទារ ដែលកើតឡើងដោយគេរស់នៅក្នុងសង្គមសេដ្ឋកិច្ច ទីផ្សារសេរី ។ ក្នុងពេលដែលស្ត្រីកម្ពុជាប្រដេញរកឱកាសទាំងនេះ គេក៏ក្លាយទៅជាផ្នែកដ៏ពេញលេញ ក្នុងការអភិវឌ្ឍនៃកម្ពុជាទាំងមូល ។



សិទ្ធិមនុស្សជាមូលដ្ឋាននៃការអភិវឌ្ឍកម្ពុជា ។ សិទ្ធិស្ត្រីគឺជាសិទ្ធិមនុស្ស ។ សិទ្ធិមនុស្សរបស់ស្ត្រី មានន័យថាបង្កើតឱ្យមាន

ឋានៈស្មើគ្នាខាងសង្គម សេដ្ឋកិច្ច វប្បធម៌ ពលរដ្ឋ និងខាងនយោបាយ សម្រាប់ស្ត្រី ក៏ដូចជាសម្រាប់បុរស ។ ស្ត្រីនៅកម្ពុជាមានចំនួន ៥២ % នៃប្រជាជនទាំងអស់ ។ ដូច្នេះនៅពេលណាដែលយើងគិតថា សិទ្ធិមនុស្សជាបញ្ហាពាក់ព័ន្ធនិងសំខាន់ យើងក៏ត្រូវតែទទួលស្គាល់សារៈសំខាន់នៃសិទ្ធិរបស់ស្ត្រីផងដែរ ។

រាជរដ្ឋាភិបាលកម្ពុជា (RCG) បានប្តេជ្ញាចិត្តជំរុញសិទ្ធិស្រីឱ្យមានការជឿនលឿន ។

ក្នុងឱកាសប្រារព្ធខួបទី ៩៦ នៃទិវាស្ត្រីអន្តរជាតិ ៨ មីនា ឆ្នាំ២០០៦ **សម្តេច ហ៊ុន សែន** នាយករដ្ឋមន្ត្រី បានទទួលស្គាល់នូវអាទិភាពនៃការលើកកម្ពស់សិទ្ធិរបស់ស្ត្រីខ្មែរ ។ សម្តេចបានសង្កត់ធ្ងន់ទៅលើតម្រូវការកែលម្អលក្ខខណ្ឌជីវភាពរស់នៅតួនាទី និងការទទួលខុសត្រូវរបស់ពួកគេ ក៏ដូចជាសារៈសំខាន់នៃការបង្អាចដល់ស្ត្រី (ផ្តល់សិទ្ធិអំណាច- empowerment)។ សម្តេចបានកត់សម្គាល់ថា ការរើសអើង និងហិង្សាប្រឆាំងស្ត្រីនិងកុមារ គឺជាបញ្ហាសាកល ហើយផលប៉ះពាល់ទាំងអស់ នៅតែជាឧបសគ្គខ្លាំងជាទីបំផុតរារាំង ប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិនៃការចូលរួមដ៏ពេញលេញ និងស្មើភាពគ្នារបស់ស្ត្រី ក្នុងសកម្មភាព សង្គម សេដ្ឋកិច្ច វប្បធម៌ និងនយោបាយ ដែលគេត្រូវតែទទួលបាន តាមសេចក្តី ប្រកាសជាសាកលអំពីសិទ្ធិមនុស្ស ។

ការប្រឈមប្រជែងទាំងឡាយដែលកម្ពុជាជួបប្រទះ នៅពេលអនាគត គឺត្រូវឈានឱ្យផុតពីព្រំប្រទល់ផ្នត់គំនិត (Stereotype) របស់ប្រពៃណី និងដោះស្រាយបញ្ហាចំពោះមុខ ដោយរួមបញ្ចូលបុរស ទៅក្នុងដំណើរសមាហរណកម្មនៃសមភាពយេនឌ័រ ។ តាមពិតស្ត្រីទាំងឡាយមិនអាចសម្រេចបាននូវសមភាពយេនឌ័រ ដោយគ្មានកិច្ចសហការ និងការចូលរួមពីបុរសបានឡើយ ។ នៅពេលដែលអ្នកបង្កើនភាពម្ចាស់ការរបស់បុរស លើរាល់ការផ្តួចផ្តើមថ្មីៗដែលលើកកម្ពស់សមធម៌ សមភាព និងការបង្អាចរបស់ស្ត្រី នៅពេលនោះហើយអ្នកនិងផ្តល់ឱកាសស្មើគ្នាទៅដល់ទាំងបុរសទាំងស្ត្រី ។ ធ្វើដូច្នោះគឺបង្កឱ្យស្ត្រី អាចទាមទារសិទ្ធិអំណាចរបស់ខ្លួន ក្នុងនាម

ជាសមាជិកនៃចំណោមអ្នកផ្តល់វិភាគទានដល់សង្គមកម្ពុជា ។

## ទស្សនៈ (concept) ជាមូលដ្ឋានអំពីសិទ្ធិមនុស្ស អ្វីទៅជាសិទ្ធិមនុស្ស?

សិទ្ធិមនុស្សមិនត្រឹមតែជាបទដ្ឋានសំខាន់ ដែលមនុស្សត្រូវការសម្រាប់រស់នៅក្នុងភាពថ្លៃថ្នូរជាមនុស្ស និងជាវិធានសម្រាប់រដ្ឋាភិបាលដោះស្រាយនូវអ្វីដែលត្រូវធ្វើ និងអ្វីដែលមិនត្រូវធ្វើ ដើម្បីគោរពដល់សិទ្ធិប្រជាពលរដ្ឋរបស់ខ្លួន ដូចដែលបានចែងនៅក្នុងសេចក្តីប្រកាសជាសាកលស្តីអំពីសិទ្ធិមនុស្ស (UDHR) តែប៉ុណ្ណោះទេ ថែមទាំងជាមូលដ្ឋានសម្រាប់សេរីភាព យុត្តិធម៌ និងសន្តិភាពទៀតផង ។ អាស្រ័យលើការយល់ដឹងតាមខ្លឹមសារខាងលើ នៅពេលមានសន្តិភាព ប្រជាជាតិមួយអាចចាប់ផ្តើមបំពេញនូវគុណជាតិដោយខ្លួនឯង ។ ដោយហេតុថាមានសន្តិភាពក្នុងព្រំដែនមួយនុះនិងនាំមកនូវស្ថេរភាពនៅក្នុងប្រទេស ហើយស្ថេរភាពនៅក្នុងប្រទេសនិងបើកផ្លូវសម្រាប់ការអភិវឌ្ឍជាបន្ត ។ ការអភិវឌ្ឍនោះនឹងនាំឱ្យមានប្រាក់ចំណូលសម្រាប់ចិញ្ចឹមសេដ្ឋកិច្ចឱ្យលូតលាស់ ចម្រុងចម្រើនសម្រាប់ទាំងអស់គ្នា ហើយញ៉ាំងចិត្តឱ្យមានក្តីសង្ឃឹមនិងអនាគតសម្រាប់មនុស្សជំនាន់ក្រោយ ។

## លក្ខណៈនៃសិទ្ធិមនុស្ស គឺ :

**សិទ្ធិមនុស្សមានជាប់សម្រាប់ជនម្នាក់ៗ :** សិទ្ធិមនុស្សមិនត្រូវបានគេទិញ រកបាន ឬទទួលជាមរតកឡើយ ។ ប្រជាជនម្នាក់ៗមានសិទ្ធិគេចាប់តាំងពីពេលកើតមក ដោយហេតុតែ គេជាមនុស្ស ។

**សិទ្ធិមនុស្សជាសាកល :** សិទ្ធិមនុស្ស គឺមានដូចៗគ្នាសម្រាប់មនុស្សរាល់រូបនៅលើលោកនេះ ដោយមិនបានប្រកាន់ពីជាតិកំណើត ភេទ សាសនា

មតិនយោបាយឬមតិដទៃទៀត ដើមកំណើត សញ្ជាតិ ឬសង្គមឡើយ ។ មនុស្សយើងរាល់រូបកើតមកមានសេរីភាពរួមទាំងមានសិទ្ធិ និងសេចក្តីថ្លៃថ្នូរស្មើៗគ្នា ។

**សិទ្ធិមនុស្សមិនអាចបែងចែកបាន** : ប្រជាជនទាំងឡាយត្រូវរស់នៅក្នុងសេចក្តីថ្លៃថ្នូរ ។ មនុស្សទាំងអស់គ្នាមានសិទ្ធិទទួលបានសេរីភាព សន្តិសុខ និងកម្រិតជីវភាពរស់នៅសមរម្យក្នុងពេលជាមួយគ្នា ។ គ្មានសិទ្ធិ មនុស្សមួយណាសំខាន់តិច ឬ ច្រើន ជាងសិទ្ធិណាមួយទៀតទេ ។ សិទ្ធិទាំងនោះជាប់ជំពាក់និងទាក់ទងគ្នាទៅវិញទៅមក ។ ចូរគិតអំពីគោលការណ៍ នៃភាពមិនអាចចែកបាន ឧបមាបីដូចជាផ្ទះឥដ្ឋ ។ ដុំឥដ្ឋនីមួយៗ នៅក្នុងផ្ទះនោះមានប្រយោជន៍និងតម្លៃស្មើៗគ្នា ហើយឥដ្ឋទាំងអស់ សុទ្ធតែទ្រទ្រង់ផ្ទះទាំងមូល ។

**សិទ្ធិមនុស្សមិនត្រូវអាចដកហូតបាន** : សិទ្ធិមនុស្ស មិនអាចត្រូវបានគេដកហូតឬលក់ដូរបានឡើយ ។ គ្មានជនណាម្នាក់មានសិទ្ធិដកហូតសិទ្ធិបុគ្គលម្នាក់ទៀតដោយមូលហេតុណាមួយឡើយ ។ ប្រជាជននៅតែមានសិទ្ធិមនុស្សទោះជាច្បាប់នៃប្រទេសរបស់គេមិនទទួលស្គាល់ ឬប្រទេសគេបានរំលោភលើសិទ្ធិទាំងនោះក្តី ។ ជាឧទាហរណ៍ នៅពេលដែលមានការប្រព្រឹត្តទាសកម្ម ទាសករទាំងឡាយនៅតែមានសិទ្ធិ សូម្បីតែសិទ្ធិទាំងនេះ ត្រូវបានគេរំលោភបំពានក្តី ។

## សិទ្ធិមនុស្សអាចចែកចេញជា ៣ ប្រភេទ :

**សិទ្ធិស៊ីវិល និង នយោបាយ** : គឺ " សំដៅទៅរក ឥស្សរភាព " ហើយរួម

មានសិទ្ធិក្នុងការរស់នៅក្នុងឥស្សរភាព និងសន្តិសុខរបស់បុគ្គល សេរីភាពចាក ផុតពីការធ្វើទារុណកម្មនិងទាសភាព សេរីភាពចូលរួមក្នុងកិច្ចការនយោបាយ សេរីភាពក្នុងការបញ្ចេញមតិ ក្នុងការសម្តែង ក្នុងការគិត ក្នុងការបញ្ចេញ មនសិការ និងក្នុងជំនឿសាសនា ព្រមទាំងសេរីភាពក្នុងការចូលរួមជាសមាគម និងការប្រមូលផ្តុំ ។

**សិទ្ធិសេដ្ឋកិច្ច និង សង្គម :** " សំដៅទៅរក សន្តិសុខ " ។ ជាឧទាហរណ៍ សិទ្ធិមាន ការងារ សិទ្ធិទទួលបានការអប់រំ សិទ្ធិរស់នៅក្នុងកម្រិតជីវភាពសមរម្យ សិទ្ធិទទួលបានស្បៀង អាហារ ទីជម្រក និងការគាំពារសុខភាព ។

**សិទ្ធិបរិស្ថាន វប្បធម៌ អភិវឌ្ឍន៍ :** សិទ្ធិនោះរួមមាន សិទ្ធិរស់នៅក្នុងបរិស្ថានមួយស្អាត និងការពារពីការបំផ្លិចបំផ្លាញ សិទ្ធិទទួលបាននូវការអភិវឌ្ឍ ផ្នែកវប្បធម៌ នយោបាយ និងសេដ្ឋកិច្ច ។

ចំពោះសិទ្ធិមនុស្សជាមូលដ្ឋានទាំងអស់ដែលបានពិភាក្សាមកខាងលើនេះ គឺមានចែងក្នុង " ច្បាប់ស្តីអំពីសិទ្ធិមនុស្ស " ដែលក្នុងនោះរួមមានអនុសញ្ញា កតិកាសញ្ញា សន្ធិសញ្ញា និងពិធីសារ ដែលបានតាក់តែងឡើងជាច្រើនឆ្នាំ ដោយអង្គការសហប្រជាជាតិ និងស្ថាប័នអន្តរជាតិ ដទៃទៀត ដូចជាសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ជាដើម (ASEAN) ។

# សេចក្តីផ្តើមអំពីអនុសញ្ញាស៊ី-ដ : ២



## ការយល់ដឹងអំពីក្របខណ្ឌការងារនៃអនុសញ្ញាស៊ី-ដ

**តើអ្វីទៅជាអនុសញ្ញាស្តីអំពីការលុបបំបាត់រាល់ទម្រង់នៃ ការរើសអើងប្រឆាំងនារី(ស៊ី-ដ)?**

ស៊ី-ដ (CEDAW) គឺជាសន្ធិសញ្ញាអន្តរជាតិ ដែលជាផ្នែកមួយនៃប្រព័ន្ធច្បាប់សិទ្ធិមនុស្សនៃសហប្រជាជាតិ។ ពេលខ្លះ យើងសំដៅលើអនុសញ្ញាស៊ី-ដ ថាជា "អនុសញ្ញារបស់ស្ត្រី (Women's Convention) ឬ "**កម្រងសិទ្ធិស្ត្រី** " (Women's Bill of Rights")។ ជាទូទៅអនុសញ្ញាស៊ី-ដ គឺជាកិច្ចព្រមព្រៀងអន្តរជាតិទូលំទូលាយមួយដែលមានបំណងចង់កែលម្អស្ថានភាពស្ត្រី ។ អនុសញ្ញាស៊ី-ដ លើកកម្ពស់ការសម្រេចបានស្មើគ្នានូវសិទ្ធរបស់ស្ត្រី ក្នុងវិស័យសេដ្ឋកិច្ចសង្គម វប្បធម៌ នយោបាយ និងសិទ្ធិស៊ីវិល ។ អនុសញ្ញានេះក៏បង្កើតឡើងនូវសិទ្ធិនានាសម្រាប់ស្ត្រី ក្នុងផ្នែកទាំងឡាយដែលមិនត្រូវបានទទួលការដោះស្រាយពីពេលមុន ក្នុងច្បាប់អន្តរជាតិ ។

### *ប្រអប់ ១.១ កិច្ចសន្យាសង្គម និងឧបករណ៍*

*ខណៈដែលកម្ពុជាផ្តល់សច្ចាប័នលើអនុសញ្ញាស៊ី-ដ នោះជាកិច្ចសន្យាសង្គមដែលរដ្ឋាភិបាលយល់ព្រមចូលជាភាគី ហើយសន្យាចំពោះស្ត្រីទាំងឡាយនៅក្នុងប្រទេសថានឹងគោរពតាមបទប្បញ្ញត្តិនានារបស់អនុសញ្ញាស៊ី-ដ ។អនុសញ្ញាស៊ី-ដជាឧបករណ៍ ហើយផ្តល់អានុភាពចំពោះស្ត្រី ដោយអះអាងថា " ជាការត្រឹមត្រូវដែលថាស្ថានភាពស្ត្រីត្រូវតែបានដោះស្រាយតាមបរិបទជានិយម ហើយថានេះជាឯកសារសិទ្ធិមនុស្សមួយ ។ ដូច្នេះសិទ្ធិរបស់ស្ត្រីនៅក្នុងកម្រងនៃឯកសារសិទ្ធិមនុស្ស ដោយស្វ័យប្រវត្តិ ។*

# គោលការណ៍ស្នូលទាំងបីនៃអនុសញ្ញា ស៊ីដ

អនុសញ្ញាស៊ី-ដ ផ្អែកលើមូលដ្ឋានក្របខណ្ឌការងារដែលឈរលើគោលការណ៍ស្នូល៣ គឺ :

- សមភាពសំខាន់ៗ
- ការរើសអើង និងការមិនរើសអើង
- កាតព្វកិច្ចរដ្ឋ

គោលការណ៍ទាំងនោះ មានលក្ខណៈពិសេសនិងគ្មានដូច មានតែក្នុងអនុសញ្ញាស៊ី-ដ ទេ ដែលផ្ដល់នូវអត្ថន័យពិសេស ដល់សិទ្ធិទាំងឡាយរបស់ស្ត្រី ។

ក្នុងផ្នែកនេះ យើងនឹងរៀនអំពីគោលការណ៍ស្នូលទាំងនេះ ។ ប៉ុន្តែគោលការណ៍ទាំងនោះ ត្រូវតែមានវត្តមានជានិច្ចនៅពេលណាដែលយើងគិតអំពី ឬព្យាយាមអនុវត្តបទប្បញ្ញត្តិពិតៗនៃអនុសញ្ញាស៊ី-ដ ។

## គោលការណ៍ទី១ សមភាពសំខាន់ៗ

ទស្សនៈនៃសមភាព មានលើសឆ្ងាយពីប្រព្រឹត្តិកម្មដូចគ្នាចំពោះ ឯកត្តជន ទាំងអស់ ។ ជាឧទាហរណ៍ នៅក្នុងស្ថានភាពមិនស្មើគ្នា សមភាពនៃប្រព្រឹត្តិកម្ម ជាការបន្តនូវភាពអយុត្តិធមិច្រើនជាងការបំបាត់នូវភាពអយុត្តិធមិ ។ ដោយមានការប្រឹងប្រែង យ៉ាងខ្ជាប់ខ្ជួនផ្ដោតចំពោះ និងកែតម្រូវអតុល្យភាពទាំងនេះ នៅពេលហ្នឹងហើយដែលយើងនឹងបំពិត(ធ្វើឱ្យពិត) នូវសមភាពពិតប្រាកដបាន ។

សមភាពសំខាន់ៗមានផ្នែកចាំបាច់ ៣ ។ រូបភាពខាងក្រោមបង្ហាញថាតើផ្នែកចាំបាច់ទាំងឡាយនេះទាក់ទិនគ្នាយ៉ាងណា ហើយថាសមភាពអាច សម្រេចបាន យ៉ាងដូចម្ដេច។

## រូបភាព ២.១ : ផ្នែកចាំបាច់នៃសមភាព

**ជំហានទី១ : សមភាពនៃកាលានុវត្តភាព :**

ស្ត្រីត្រូវបានផ្តល់កាលានុវត្តភាពដូចបុរសដែរ ប៉ុន្តែធ្វើរបៀបនេះ នៅមិនទាន់គ្រប់គ្រាន់ទេ បើសិនពួកគេគ្មានមធ្យោបាយ ដើម្បីទទួលបាននូវកាលានុវត្តភាពនោះទេ ។

**ជំហានទី២ : សមភាពទទួលបាននូវកាលានុវត្តភាព :**

គឺថាស្ត្រីទាំងឡាយមានសិទ្ធិទទួលបានការប្រើប្រាស់ធនធាន របស់ស្រុកទេសដូចៗគ្នានឹងបុរសដែរ ថែមទាំងមានក្របខណ្ឌការងារ ដែលធានាកិច្ចការពារ ដោយច្បាប់ទាំងឡាយ និងគាំទ្រដោយស្ថាប័នទាំងឡាយ ។

**ជំហានទី៣ : សមភាពនៃលទ្ធផល**

រដ្ឋត្រូវធានាឱ្យបំពិតនូវការប្រតិបត្តិ សិទ្ធិ ដូច្នេះរដ្ឋត្រូវ តែបង្ហាញនូវលទ្ធផល ទាំងឡាយ មិនមែននៅត្រឹមតែក្របខណ្ឌការងារសមធម៌ដែលមានថែងល្អតែលើក្រដាសប៉ុណ្ណោះទេ ។

**រូបភាពខាងក្រោមនេះបង្ហាញអំពីគោលការណ៍នៃសមភាពទាំងបី :**

**មានមាគ៌ាបីខុសៗគ្នាដើម្បីកែតម្រូវអតុល្យភាពទាំងឡាយនោះ មាគ៌ាទាំងនេះគឺ :**

## ១. មាគ៌ាបែបសណ្ឋាននៃសមភាព (Formal Approach of Equality)



មាគ៌ានៃសមភាពនេះផ្អែកលើទស្សនទានបញ្ញត្តិ ដែលថាបុរសនិងស្ត្រីទាំងអស់ដូចគ្នា ហើយការដែលមើលទៅឃើញថាជាខុសគ្នានិងនាំមកនូវវិសមភាព ។ ដូច្នេះហើយគេត្រូវតែប្រព្រឹត្តចំពោះបុរស និងនារីឱ្យដូចៗគ្នា ដោយគ្មានការបែងចែក ។

តាមគំរូនេះ សេចក្តីត្រូវការជាពិសេសរបស់ស្ត្រីទាំងឡាយត្រូវបានគេមើលរំលងហើយ ស្ត្រីត្រូវបានដាក់ឱ្យរងគ្រោះថ្នាក់ ជារឿយៗមិនអាចនឹងទទួលបានឱកាសល្អ ដោយសារអមិត្តភាពនៃបរិយាកាសជុំវិញខ្លួន ពួកគេផង ។

## ២. មាគ៌ាការពារនិយមនៃសមភាព (Protectionist Approach to Equality)



មាគ៌ាការពារនិយមនៃសមភាព ទទួលស្គាល់នូវភាពខុសគ្នារវាងបុរសនិងស្ត្រី មានដូចជាភាពខុសគ្នាខាងជីវសាស្ត្រ(សរីរាង្គ)តែមើលភាពខុសគ្នាទាំងនេះឃើញ ថាជាភាពទន់ខ្សោយ ។ ដោយមានចងចាំទុកក្នុងចិត្ត មិនភ្លេចនូវភាពខុសគ្នាទាំងឡាយនេះ គេស្នើឱ្យមានប្រព្រឹត្តិកម្មខុសៗគ្នា ដោយត្រួតត្រាលើស្ត្រី តែមិនកែតម្រូវបរិយាកាសទេ ឬក៏ផ្តល់ការគាំទ្រដល់ស្ត្រីឱ្យអាចទប់ទល់នឹងបរិយាកាសដែលគ្មានសុវត្ថិភាពនោះទេ ។ ជាជាងធ្វើឱ្យមានការបំលែងសង្គម មាគ៌ានេះរឹតបន្តឹង និងរឹតត្បិតការមិនឱ្យទទួលបានកាលានុវត្តភាពស្មើៗគ្នាទៅវិញ ។

## ៣. មាគ៌ាកែតម្រូវនៃសមភាព (The Corrective Approach to Equality)



មាគ៌ាកែតម្រូវនៃសមភាពនេះ ទទួលស្គាល់ថាមានភាពខុសគ្នារវាងបុរសនិងស្ត្រី ដោយចោទសួរអំពីមូលដ្ឋាននៃភាពខុសៗគ្នារវាងបុរសនិងស្ត្រី ហើយឆ្លើយតបដោយប្រព្រឹត្តិកម្មខុសៗគ្នា ដែលតម្រង់ទៅរកការកែតម្រូវភាពរណប (ស្ថានភាពទាប) របស់ស្ត្រី ។

មាគ៌ានេះអោបក្រសោបនូវគ្រប់គំនិតផ្តួចផ្តើមអំពីច្បាប់ គោលនយោបាយ កម្មវិធី និងសេវាទាំងឡាយដែលនឹងនាំទៅរកសមភាពនៃកាលានុប្បវត្តភាព ការទទួលបាន រួមទាំងលទ្ធផលផង ។ មាគ៌ានេះដឹងថាប្រព្រឹត្តិកម្ម ឬចម្លើយទាំងឡាយណា ដែលមិនបានយកភាព

ខុសគ្នាមកគិតគូផង និងទទួលបាននូវលទ្ធផលមិនស្មើគ្នាសម្រាប់បុរសនិងស្ត្រី ។

អនុសញ្ញាស៊ីដ លើកកម្ពស់គំរូនៃសមភាពជាសំខាន់ ដែលរាប់បញ្ចូលទាំងផ្នែកពេញលក្ខណៈនានាផងដែរ ។ គំរូកែតម្រូវនេះ ស្របគ្នានឹងទស្សនប្បញ្ញត្តិ (Vision) របស់អនុសញ្ញាស៊ីដ ហើយដាក់កាតព្វកិច្ចឱ្យកែតម្រូវបរិយាកាសជុំវិញ ដែលនាំឱ្យស្ត្រីចាញ់ប្រៀប និងធ្វើឱ្យទីលានប្រជែងមានភាពស្មើៗគ្នាចំពោះបុរសនិងស្ត្រី ។

## គោលការណ៍ទី២ ការរើសអើង/ការមិនរើសអើង

បន្ទាប់ពីយើងបានយល់ដឹងពីសមភាពមក ការយល់ដឹងពីគោលការណ៍ស្នូល នៃការមិនរើសអើងមានសារៈសំខាន់ណាស់ ។ យោងតាមមាត្រា ១ នៃអនុសញ្ញាស៊ីដ ៖

*" ការរើសអើងប្រឆាំងស្ត្រីភេទ" សំដៅដល់ការប្រកាន់បែងចែក ការផាត់ចេញ ឬការរឹតត្បឹតផ្អែកលើភេទ ដែលមានអានុភាព ឬមានបំណងធ្វើឱ្យខូចខាត ឬធ្វើឱ្យមោឃៈនូវការទទួលស្គាល់ ការអាស្រ័យផល ឬការប្រើប្រាស់ដោយស្ត្រី ដោយឥតគិតដល់ស្ថានភាពអាពាហ៍ពិពាហ៍របស់ស្ត្រី ផ្អែកលើមូលដ្ឋានសមភាពរវាងបុរសនិងស្ត្រីនូវសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋាន ក្នុងវិស័យនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ និងស៊ីវិល ឬក្នុងវិស័យដទៃទៀត ។ "*

មានសន្ធិសញ្ញាស្តីអំពីសិទ្ធិមនុស្សច្រើន មិនមែនមានត្រឹមតែមួយនោះទេដែលហាមប្រាមការរើសអើង ក្នុងនោះក៏មានរាប់បញ្ចូលទាំងអនុសញ្ញាស៊ីដផងដែរ ។ សន្ធិសញ្ញាទាំងអស់នោះហាមប្រាមចំណាត់ការខុសៗគ្នា ក្នុងការធានាសិទ្ធិ ដល់ឯកត្តជនទាំងឡាយ ដោយឈរលើមូលដ្ឋានភេទ ។ ក៏ប៉ុន្តែអនុសញ្ញាស៊ីដឈានឆ្ងាយទៅមុខទៀត ដើម្បីផ្តល់ការពន្យល់ និងនិយមន័យទូលំទូលាយនៃការរើសអើង ជាពិសេសប្រឆាំងនឹងស្ត្រី ។ សន្ធិសញ្ញានេះសំដៅទៅរក "ការបែងចែក" ឬ "ការរើសអើង" ផ្អែកលើមូលដ្ឋានភេទ ដែលអនុវត្តបាន ទៅលើភាពខុសគ្នា

ក្នុងប្រព្រឹត្តិកម្មណាមួយក៏បាន ។

រដ្ឋធម្មនុញ្ញកម្ពុជាមិនបានផ្ដល់និយមន័យច្បាស់លាស់ឱ្យវាក្យស័ព្ទ "រើសអើងប្រឆាំងស្ត្រីភេទ" រីឯច្បាប់ជាតិផ្សេងទៀត ក៏ពុំបានផ្ដល់និយមន័យនេះផងដែរ ។ រហូតមកដល់ពេលនេះ រដ្ឋាភិបាលកម្ពុជា បានពឹងផ្អែកទៅលើនិយមន័យ ដែលបានផ្ដល់ក្នុងអនុសញ្ញាស៊ីដ-ដ មកធ្វើជាមូលដ្ឋានសម្រាប់ព្រាងច្បាប់ជាតិនានា ដើម្បីធានាឱ្យមានសិទ្ធិស្មើគ្នារវាងបុរស-ស្ត្រី នៅគ្រប់វិស័យ ។ បច្ចុប្បន្ន គ្មានច្បាប់ណាមួយចែងជាក់លាក់ថា ការរើសអើងប្រឆាំងស្ត្រីភេទជាបទល្មើសឧក្រិដ្ឋនោះទេ ។ ថ្វីត្បិតតែពាក្យ " រើសអើង " ត្រូវបានទទួលស្គាល់ និងប្រើប្រាស់ក្នុងឯកសារច្បាប់ទាំងឡាយយ៉ាងណាក្តី ក៏នៅមានបញ្ហាជាច្រើនក្នុងការប្រតិបត្តិនៅឡើយ ។ ជាឧទាហរណ៍ មានភាពខុសគ្នាក្នុងកាំប្រាក់ថ្លៃឈ្នួលផ្ដល់ឱ្យបុរស និងស្ត្រី ធ្វើការងារដូចគ្នានៅកម្ពុជា ។ ជាមធ្យម ក្រោយពីបានគិតដល់បទពិសោធន៍ គិតដោយអាយុ និងចំណេះដឹងរបស់បុគ្គលម្នាក់ៗ បុរសបានថ្លៃឈ្នួលខ្ពស់ជាងស្ត្រី ៣៣% ។ គម្លាតដ៏ធំរវាងបុរស និងស្ត្រីមានក្នុងចំណោមអ្នកធ្វើការដែលគ្មានចំណេះដឹង អាយុពី១៥-២៩ឆ្នាំ ដែលមានកម្រិត ទៅដល់៧៥% រីឯគម្លាតមានតិចតួចបំផុត មានក្នុងចំណោមអ្នកធ្វើការអាយុពី៣០-៣៩ឆ្នាំ ដែលមានចំណេះដឹងថ្នាក់អនុវិទ្យាល័យ ។

វិសាលភាពនៃការរើសអើងគ្របដណ្ដប់ដោយសន្ធិសញ្ញាស៊ីដ-ដ មិនមានកំណត់តែទៅលើវិស័យសាធារណៈនៃជីវិតនោះឡើយ ។ អនុសញ្ញានេះ គ្របដណ្ដប់កិច្ចការនានា ក្នុងវិស័យនយោបាយ វិស័យសេដ្ឋកិច្ច វិស័យសង្គម វិស័យវប្បធម៌ វិស័យស៊ីវិល និងវិស័យផ្សេងៗទៀត ហើយថែមទាំងរាប់បញ្ចូលទាំងកិច្ចនៃអ្នកដើរតួឯកជន ដូចជាឯកត្តជន ព្រមទាំងផ្នែកធុរកិច្ចឯកជន គ្រួសារ ក៏ដូចជាសហគមន៍ផងដែរ ។ វាគ្របដណ្ដប់ លើច្បាប់ដែលបានតាក់តែង លើការសន្មត និង បទដ្ឋានសង្គម វប្បធម៌ អំពីតួនាទីទាំងឡាយ ដែលបុរស និងស្ត្រីបានទទួលឥទ្ធិពល ។

## ទស្សនៈនៃការមិនរើសអើង អនុវត្តនៅលើ ៖

- **កិច្ចដោយចេតនា ៖** គឺជាកិច្ចដែលបានគ្រោងទុកជាមុន ធ្វើឡើងដោយសេចក្តីបំណងណាមួយ ហើយដែលមិនមែនកើតដោយចៃដន្យ ដែលបានរំពៃគិតទុកជាមុន ។
- **កិច្ចដោយអចេតនា ៖** គឺកិច្ចដែលបានកើតឡើងដោយគ្មានការគ្រោងទុក មិនកើតឡើងដោយឆន្ទៈ គ្មានការរំពៃគិតទុកជាមុន និងធ្វើដោយគ្មានសេចក្តីបំណង ។
- **អ្នកដើរតួសាធារណៈ ៖** រួមមានមន្ត្រីរដ្ឋាភិបាល អ្នកបម្រើការស៊ីវិល អ្នកមានភារកិច្ចដទៃទៀត ។
- **អ្នកដើរតួឯកជន ៖** មានន័យថាជាអង្គភាពមិនមែនរដ្ឋ រួមមានអង្គការមិនមែន រដ្ឋាភិបាល សាជីវកម្ម និងពលរដ្ឋទាំងឡាយ ។

## តាមនីតិន័យ (De jure) ធៀបនឹង តាមព្រឹត្តន័យ (De facto)

និយាយឱ្យងាយយល់វាក្យសព្ទ "**តាមនីតិន័យ**" (de jure) និង "**តាមព្រឹត្តន័យ**" (de facto) ត្រូវបានយកមកជំនួស "តាមច្បាប់" និង "តាមការពិត" ។ ជាឧទាហរណ៍នៃការរើសអើង តាម**នីតិន័យ** ប្រសិនបើមានច្បាប់ដែលហាមឃាត់ ស្ត្រីមិនឱ្យបោះឆ្នោតនៅពេលដែលបុរសត្រូវបានអនុញ្ញាតឱ្យបោះ ។ ក្នុងករណីនេះគឺច្បាប់ខ្លួនឯងដែលរើសអើងប្រឆាំងនិងស្ត្រី ។ ច្បាប់បង្កើតនូវការរើសអើងបែបរចនាសម្ពន្ធដែលក្នុងនោះស្ត្រីមិនអាចបោះឆ្នោតបាន ។ អស់រយៈពេលជាច្រើនឆ្នាំ សិទ្ធិបោះឆ្នោះត្រូវបានបំរុងទុកឱ្យតែបុរសៗ ដោយផាត់ចេញអ្នកឯទៀត ។ នៅប្រទេសមូស្លីមខ្លះ ស្ត្រីនៅមិនទាន់បានទទួលការអនុញ្ញតឱ្យបោះឆ្នោតនៅឡើយ ។ ទាំងនោះគឺជាការរើសអើងដែលមានថ្លែងច្បាស់ៗ នៅក្នុងច្បាប់ដែលហៅថា ការរើសអើង**តាមនីតិន័យ** ។

ការរើសអើង**តាមព្រឹត្តន័យ**ជាការរើសអើង បែបប្រតិបត្តិដែលយើងសង្កេតឃើញនៅ

ក្នុងសង្គម ។ ជាឧទាហរណ៏នៃការរើសអើង**តាមព្រឹត្តន័យ** ប្រសិនបើស្ត្រីនិងបុរសអាចឈរឈ្មោះឱ្យគេបោះឆ្នោតនៅពេលដែលតំណាងឱ្យស្ត្រីភេទមានត្រឹមតែ ១២% នៅកម្ពុជា ។ ទោះជាមានច្បាប់ធានាឱ្យមានកាលានុវត្តភាពស្មើគ្នា សម្រាប់ស្ត្រីនិងបុរសយ៉ាងណាក៏ដោយ ក៏ការរើសអើងប្រឆាំងនិងស្ត្រីនៅតែមាន ដែលផាត់ស្ត្រីតាមបែបប្រព័ន្ធចេញពីដំណើរការសម្រេចចិត្ត ។

**រូបភាព២.២ តើនៅពេលណាដែលភាពខុសគ្នា និង ប្រព្រឹត្តិកម្មខុសគ្នាខាងផ្នែកយេនឌ័របង្កឱ្យមាន ការរើសអើង តាមអនុសញ្ញាស៊ី-ដ ?**

ប្រសិនស្ថានការនោះបណ្តាលឱ្យមានលទ្ធផលដូចតទៅ :




**ឧទាហរណ៏ :**

- ដោយសារនាង **ធារី** ជាកុមារី នាងមិនមានសុវត្ថិភាពទៅចូលរៀន ។ ដូច្នេះគេមិនអនុញ្ញាតឱ្យនាងទៅ សាលារៀនឡើយ ។
- ដោយសារនាង **ចន្ទនី** ជាកុមារី នាងមិនអាចទៅសាលារៀនទាន់ពេលវេលា ពីព្រោះនាងរវល់មើលថែបងប្អូននៅផ្ទះ ។
- នាង **ធារី** គ្មានសង្ឃឹមថានាងនឹងអាចបានទៅរៀនសូត្រឡើយ ។
- **វ៉ាន់នី** មិនត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់សាលារៀននៅក្នុងឃុំរបស់នាងឡើយ ។

## ធាតុផ្សំនាំឲ្យមានដែលបង្កើតការរើសអើង

យោងតាមអនុសញ្ញាស៊ី-ដ ការរើសអើងកើតឡើងតាមលំដាប់នៃព្រឹត្តិការណ៍ដូចខាងក្រោម ៖

- **មនោគមន៍វិជ្ជា ៖**

  ការសន្មតនានាក្នុងវិស័យយេនឌ័រអំពីតួនាទី និងសមត្ថភាពរបស់បុរស និងស្ត្រី ដែលមានរាប់បញ្ចូល មិនត្រឹមតែប្រព្រឹត្តិកម្មខុសគ្នា ដោយផ្អែកលើភេទប៉ុណ្ណោះទេ ក៏ប៉ុន្តែលាតសន្ធឹងដល់ការសន្មតនានា ក្នុងវិស័យសង្គម វប្បធម៌ ដែលភ្ជាប់ទៅនឹងភារៈនៃខ្លួនជាស្ត្រីផងដែរ ។

- **កិច្ច ៖**

  ប្រព្រឹត្តិកម្មខុសគ្នា ការរឹតត្បិត ឬផាត់ចេញ ដែលអាចមានឥទ្ធិពលអវិជ្ជមានដល់សិទ្ធិ និងសេរីភាព ។






**ការរើសអើងដោយផ្ទាល់**

លទ្ធផលចេញពីកិច្ចដែលគេឆ្លៃប្រឌិត ដោយមានបំណងប្រព្រឹត្តខុសប្លែក ពីមុនចំពោះស្ត្រី

**ការរើសអើងដោយប្រយោល**

លទ្ធផល ដែលចេញមកពីលក្ខខណ្ឌដែលមើលទៅឃើញដូចជាអព្យាក្រឹត ឬការតម្រូវ ដែលមានឥទ្ធិពលរើសអើងលើស្ត្រី ដោយគ្មានចេតនា

- **លទ្ធផល :**

ការធ្វើឱ្យខូចខាត ឬការធ្វើឱ្យមោឃៈ នូវការទទួលស្គាល់ ការអាស្រ័យផល ឬការប្រើប្រាស់សិទ្ធិ ឬសេរីភាព ទាំងឡាយ ។



## ប្រព្រឹត្តិកម្មខុសគ្នា

ចលតភាពជាសាធារណៈដោយសេរីចំពោះ
បុរស ស្លៀកពាក់យ៉ាងមេចក៏បានតែ
ចំពោះ ស្ត្រីវិញ ស្លៀកពាក់
បានតែតាមបែបប្រពៃណី



## ការរឹតត្បិត

ចលតភាពជាសាធារណៈដោយសេរីចំពោះ
ស្ត្រីបាន តែនៅពេលថ្ងៃ តែគ្មានការរឹតត្បិត
បែបនោះទេចំពោះបុរស ។



**ការផាត់ចេញ ៖**

ចលតភាពជាសាធារណៈចំពោះស្ត្រីបាន លុះត្រាតែមានបុរសអមដំណើរផង

ដូចដែលលោកអ្នកអាចដឹងបានថា អនុសញ្ញាស៊ីដ-ដអំពាវនាវឱ្យមានការបំបាត់ចោលរាល់សណ្ឋាននៃការរើសអើងទាំងឡាយ ដោយផ្អែកលើនិយមន័យទូលំទូលាយនេះជាមូលដ្ឋាន ។ អនុសញ្ញានេះសង្កត់ធ្ងន់លើការមិនរើសអើង ហើយដោយរួមផ្សំជាមួយនឹងគោលការណ៍សមភាពពិតៗ ដែលផ្តល់ឱ្យអនុសញ្ញានេះនូវមាត្រាដ៏ទូលំទូលាយមួយ ។ ការរួមបញ្ចូលនូវកត្តានានាខាងលើនេះ នឹងបានទៅជាក្របខណ្ឌការងារ ដ៏មានឥទ្ធិពលមួយ ដើម្បីបំបិតសិទ្ធិទាំងឡាយរបស់ស្ត្រី ។

## គោលការណ៍ទី៣ ៖ ភាតព្វកិច្ចរដ្ឋភាគី

អនុលោមតាមអនុសញ្ញាស៊ីដ-ដ កាតព្វកិច្ចរបស់រដ្ឋភាគី ចងភ្ជាប់ជាច្បាប់ឱ្យប្រតិបត្តិតាម ។

### មាត្រា ២៦ នៃអនុសញ្ញាទីក្រុងវីយែន ស្តីអំពីច្បាប់នៃសន្ធិសញ្ញា (ឆ្នាំ ១៩៦៩) ចែងថា ៖

*" រាល់សន្ធិសញ្ញាដែលចូលជាធរមាន ចងភ្ជាប់ជាច្បាប់ឱ្យប្រតិបត្តិតាមដោយភាគីទាំងឡាយនៃសន្ធិសញ្ញាទាំងនោះ ហើយត្រូវតែបានយកទៅប្រតិបត្តិតាម ក្នុងជំនឿដ៏ល្អប្រពៃ "*

### មាត្រា ២៧ ចែងថា ៖

*" ភាគីមួយមិនអាចលើកឡើងពីបទប្បញ្ញត្តិទាំងឡាយនៃច្បាប់ក្នុងប្រទេសរបស់ខ្លួន មកធ្វើជាការអះអាង ឱ្យខ្លួនត្រូវ ក្នុងខណៈមានការខកខានមិនបានអនុវត្តសន្ធិសញ្ញាឡើយ "*

នេះមានន័យថារដ្ឋភាគី មានការទទួលខុសត្រូវតាមផ្លូវច្បាប់ដើម្បីប្រតិបត្តិតាមគោលការណ៍ និងមាត្រា ទាំងឡាយនៃច្បាប់អន្តរជាតិ ដែលខ្លួនបានផ្តល់សច្ចាប័ន ។ កម្ពុជាបានចូលជាភាគីនៃអនុសញ្ញាស៊ី-ដក្នុងឆ្នាំ១៩៩២ ។ ការខកខានមិនបានបំពេញកាតព្វកិច្ចរបស់រដ្ឋភាគី គឺធ្វើឱ្យមូលដ្ឋាននៃច្បាប់ សន្ធិសញ្ញាអន្តរជាតិចុះខ្សោយ ។

## តើកម្ពុជាបានចូលជាភាគីនៃអនុសញ្ញាស៊ី-ដ នៅពេលណា?

កម្ពុជាបានផ្តល់សច្ចាប័នឱ្យអនុសញ្ញាស៊ី-ដនូវថ្ងៃទី ១៥ ខែតុលា ឆ្នាំ ១៩៩២ ដោយគ្មាន **ការបម្រុងទុក**អ្វីឡើយ ។ " **ការបម្រុងទុក** " នៅក្នុងច្បាប់អន្តរជាតិ មានន័យថាជាការលើកលែងនានា ដែលរដ្ឋភាគីនៃសន្ធិសញ្ញា/អនុសញ្ញាបានធ្វើ នេះមានន័យថាយូរឬឆាប់រដ្ឋភាគីនោះនឹងដកចេញ នូវការបម្រុងទុកទាំងឡាយរបស់ខ្លួន ។ កម្ពុជាក៏មិនទាន់ផ្តល់សច្ចាប័នឱ្យ **ពិធីសារជម្រើស** នៃអនុសញ្ញាស៊ី-ដ នៅឡើយទេ។ ទាក់ទងនិងពិធិសារជម្រើសនៃអនុសញ្ញាស៊ី-ដ ដែលអនុញ្ញាតឱ្យស្ត្រីជាឯកត្តជន ឬជាក្រុមធ្វើការប្រាស្រ័យទាក់ទងផ្ទាល់ជាមួយគណៈកម្មាធិការស៊ី-ដ អំពីការរំលោភលើសិទ្ធិខ្លះៗនោះ ប្រទេសកម្ពុជាមិនទាន់បានផ្តល់សច្ចាប័នឱ្យនៅឡើយទេ ។

រូបភាព ២. ៣ កាតព្វកិច្ចរបស់រដ្ឋភាគីចំពោះអនុសញ្ញាស៊ី-ដ




## តើកម្ពុជាមានកាតព្វកិច្ចអ្វីខ្លះត្រូវធ្វើ ក្នុងតួនាទីជារដ្ឋភាគី?

កម្ពុជាមានកាតព្វកិច្ចចាត់កិច្ចការដើម្បី **“ធានា”** ថាច្បាប់និងការប្រតិបត្តិទាំងឡាយរបស់ស្រុកទេស ស្របគ្នានឹងគោលការណ៍នៃសន្ធិសញ្ញា ហើយអនុវត្តការតាក់តែងច្បាប់បន្តបន្ទាប់ ដែលនៅក្នុងនោះ ការរើសអើង ត្រូវបានកំណត់និយមន័យ និងហាមប្រាម ហើយកម្មវិបាក (sanction) ត្រូវបានដាក់ជាកំហិត ។ តាមរយៈនោះផងដែរ

កាតព្វកិច្ចវិជ្ជមាន របស់រដ្ឋត្រូវបានកំណត់សម្គាល់ ព្រមជាមួយនឹងការរៀបចំស្ថាប័ននានា។

ជាឧទាហរណ៍ ច្បាប់ជាតិជាច្រើនដូចជាច្បាប់ការងារឆ្នាំ ១៩៩៧ មានធានាបន្ថែមអំពីសិទ្ធិរបស់ ស្ត្រីក្នុងវិស័យដាច់ដោយឡែកទាំងឡាយផងដែរ ។

កាតព្វកិច្ចទាំងឡាយរបស់រដ្ឋ រួមមានការជំរុញសមភាព និងបំបាត់ការរើសអើង ។ អនុសញ្ញាស៊ី-ដ ទទួលស្គាល់ថាតាមប្រវត្តិសាស្ត្រ ស្ត្រីបានទទួលការរើសអើង និងជាអ្នកចាញ់ប្រៀបក្នុងសង្គម ។ មធ្យោបាយដើម្បីដកចេញនូវភាពជាអ្នកចាញ់ប្រៀប នេះគឺមានតែការអនុវត្តនូវ " វិជ្ជមានកិច្ច " ឬក៏ដូចដែលមានយោងក្នុង អនុសញ្ញាស៊ី-ដ ដែលហៅថាជា " វិធានការពិសេស "។ ទាំងពីរនេះ ជាផ្នែកពិសេសនៃកម្មវិធី ដើម្បីសម្រេចបាននូវសមភាពពិតៗ សម្រាប់ស្ត្រីក្រោមអនុសញ្ញាស៊ី-ដ ។



ទីលានប្រជែងមិនស្មើគ្នា

អនុសញ្ញាស៊ី-ដ បញ្ចូលនូវរបៀបពិសេសសម្រាប់កំណត់និយមន័យនៃការរើសអើង និង សមភាព ។ អនុសញ្ញា ស៊ី-ដ ដែលជាក្របខណ្ឌច្បាប់វិជ្ជមានមួយសម្រាប់សិទ្ធិស្ត្រី មិនប្រគល់សិទ្ធិដល់ស្ត្រីជាស្វ័យប្រវត្តិនោះទេ ។ ការតស៊ូមតិសម្រាប់ការអនុវត្តបទប្បញ្ញត្តិ អនុសញ្ញា ស៊ី-ដ ត្រូវផ្សាភ្ជាប់ទៅនឹងអាណត្តិអន្តរជាតិសម្រាប់សមភាព និង ការមិនរើសអើងនៅកម្រិតមូល-ដ្ឋាន ។



វិជ្ជមានកិច្ច ៖ ធ្វើឱ្យលានប្រជែងស្មើគ្នាសម្រាប់ទាំងអស់គ្នា

ការយល់ដឹងអំពីទស្សនទានបញ្ញត្តិជាមូលដ្ឋានទាំងឡាយនេះ ជាអ្នកនាំសារមកមុនការបង្កើតក្របខណ្ឌការងារនៃការទទួលខុសត្រូវសិទ្ធិ បទប្បញ្ញត្តិ គណនេយ្យភាព និងគោលបំណងនានា ។ បន្ថែមលើការរក្សាជំហរឯករាជ្យជាទស្សនទានបញ្ញត្តិមួយដោយ ឡែកច្បាស់លាស់ ។ ទោះជាយ៉ាងណាក៏ដោយ ទស្សនទានបញ្ញត្តិនិមួយៗ ក៏នៅតែជាប់ទាក់ទងគ្នាជាមួយទស្សនទានបញ្ញត្តិដទៃទៀត ដោយពង្រឹងគ្នាទៅវិញទៅមកដើម្បី កសាងមូលដ្ឋានគ្រឹះ នៃអនុសញ្ញាស៊ី-ដ ។

# ក្របខណ្ឌការងារ និង ច្បាប់ទាំងឡាយ :

# ទំនាក់ទំនងរវាងសិទ្ធិស្ត្រី និងរដ្ឋធម្មនុញ្ញកម្ពុជា

៣

*" ប្រជាពលរដ្ឋខ្មែរ មានភាពស្មើគ្នាចំពោះមុខច្បាប់ ទទួលនូវសិទ្ធិដូចគ្នា មានសិទ្ធិ សេរីភាព និងករណីកិច្ចដូចគ្នាទាំងអស់ ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿសាសនា និន្នាការនយោបាយ ដើមកំណើតជាតិ ឋានៈសង្គម ធនធាន ឬស្ថានភាពឯទៀតឡើយ ។"*

**រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា**

( កថាខណ្ឌ ២-មាត្រា ៣១- ជំពូក៣)

រដ្ឋធម្មនុញ្ញ គឺជាឯកសារច្បាប់សំខាន់បំផុត ហើយច្បាស់ជាមានចែងអំពីគោលការណ៍សមភាពយេនឌ័រ ។ រដ្ឋធម្មនុញ្ញ ជាច្បាប់កំពូលនៃប្រទេសកម្ពុជាដែលច្បាប់ជាតិទាំងឡាយត្រូវតែស្របតាមច្បាប់ កំពូលនេះ ។ រដ្ឋធម្មនុញ្ញនេះសំខាន់ណាស់សម្រាប់សិទ្ធិមនុស្ស ព្រោះថាមានចែងបទប្បញ្ញត្តិមួយចំនួន ដែលនិយាយទាក់ទងដោយផ្ទាល់ទៅនឹង សិទ្ធិមនុស្ស ហើយតម្រូវឱ្យបញ្ចូលទៅក្នុងច្បាប់របស់ជាតិនានា នូវកាតព្វកិច្ចជាអន្តរជាតិរបស់កម្ពុជាចំពោះសិទ្ធិមនុស្ស ។

សិទ្ធិទាំងអស់ដែលធានាដោយរដ្ឋធម្មនុញ្ញ ចំពោះប្រជារាស្ត្រកម្ពុជា មានរាប់បញ្ចូលទាំងបុរស ទាំងស្ត្រី ដូចមានចែងក្នុង :

**បុព្វកថា** : *"យើង ប្រជារាស្ត្រខ្មែរ ... រក្សាការពារ កសាងទឹកដីកម្ពុជា អធិបតីថ្លៃថ្លា និងអារ្យធម៌អង្គរបវរ ... ឡើងវិញ ផ្អែកលើប្រព័ន្ធ ប្រជាធិបតេយ្យ សេរីពហុបក្ស ធានាសិទ្ធិមនុស្ស គោរពច្បាប់ទទួលខុសត្រូវខ្ពស់ ចំពោះវាសនាអនាគតជាតិឱ្យបាន ឈានឡើង រីកចំរើន លូតលាស់ សម្បូររុងរឿង ជានិច្ចនិរន្តរ៍ ។"*

ម៉្យាងទៀត ច្បាប់កំពូលនេះថែមទាំងជ្រើសតាំងអ្នករក្សា/ការពារសិទ្ធិដែលមិនអាចដកហូតបាន ហើយដែលបានជូន ទៅប្រជាពលរដ្ឋទាំងអស់ ដូចមានថ្លែងក្នុង ៖

**មាត្រា ៨ ៖**

> "*ព្រះមហាក្សត្រ ទ្រង់ជាអ្នកធានាឯករាជ្យជាតិ អធិបតេយ្យ និងបូរណភាពទឹកដីនៃ ព្រះរាជាណាចក្រកម្ពុជា ទ្រង់ជាអ្នកធានាការគោរពសិទ្ធិ និងសេរីភាពរបស់ ប្រជាពលរដ្ឋ និងការគោរព សន្ធិសញ្ញាអន្តរជាតិ*" (កថាខណ្ឌ ២)

ប្រទេសកម្ពុជាទទួលខុសត្រូវ ក្នុងការអនុវត្តយ៉ាងសកម្មនូវគោលការណ៍នៃសមភាពរវាងស្ត្រី និងបុរស ដោយចូលជាភាគី និងទទួលស្គាល់ នូវសន្ធិសញ្ញា អនុសញ្ញាអន្តរជាតិ ផ្សេងៗ ដូចមានចែងក្នុង ៖

**មាត្រា ៣១ ៖**

> "*ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្ស ដូចមានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកល ស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញា ព្រមទាំងអនុសញ្ញា ទាំងឡាយទាក់ទង ទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ*" ។ (កថាខណ្ឌ ១)

ដោយការយល់ដឹងពីការប្តេជ្ញាចិត្តឱ្យមានសមភាពគ្រប់ប្រភេទ ជាពិសេសសម្រាប់ស្ត្រី ដែលមានចែង ក្នុងរដ្ឋធម្មនុញ្ញរបស់យើង កម្ពុជាប្តេជ្ញាចិត្តឱ្យមានសមភាពសម្រាប់ស្ត្រីមិនគ្រាន់តែតាមរយៈច្បាប់អន្តរជាតិប៉ុណ្ណោះទេ តែក៏តាមរយៈរដ្ឋធម្មនុញ្ញរបស់ខ្លួនផងដែរ ។ (សូមមើល តារាង ៣.១)

**តារាង ៣.១ : តារាងប្រៀបធៀប រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និង អនុសញ្ញា ស៊ី-ដ**

| បទប្បញ្ញត្តិរដ្ឋធម្មនុញ្ញឆ្លុះបញ្ចាំងពីសិទ្ធិមនុស្ស និងសិទ្ធិស្ត្រី | មាត្រានៃអនុសញ្ញា ស៊ី-ដ ដែលឆ្លើយតប |
|---|---|
| **មាត្រា ៣២ :**<br>*" ជនគ្រប់រូបមានសិទ្ធិរស់រានមានជីវិត មានសេរីភាព និង មានសន្តិសុខផ្ទាល់ខ្លួន ។ "*<br>(កថាខណ្ឌ ១) | **មាត្រា ៣ : ការធានាសិទ្ធមនុស្សជាមូលដ្ឋាន**<br>*ក្នុងគ្រប់វិស័យជាពិសេសវិស័យនយោបាយ សង្គមកិច្ច សេដ្ឋកិច្ច និងវប្បធម៌ រដ្ឋត្រូវចាត់វិធានការសមស្របទាំងអស់រួមមានការធ្វើច្បាប់ផងដើម្បីធានាការអភិវឌ្ឍន៍ និងការរីចំរើនពេញលេញរបស់ស្ត្រី* |
| **មាត្រា ៣៤ :**<br>*"ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិបោះឆ្នោត និងអាច ឈរឈ្មោះឱ្យគេបោះឆ្នោត ។ "*<br>(កថាខណ្ឌ ១) | **មាត្រា ៧ : សិទ្ធិមាន សមភាពក្នុងវិស័យនយោបាយ និងសាធារណនៃជីវិត**<br>*"រដ្ឋភាគីត្រូវប្រកាន់យកវិធានការសមស្រប ដើម្បីលុបចោលរាល់ការរើសអើង ប្រឆាំងនឹងស្ត្រីក្នុងជីវភាពនយោបាយ និងសាធារណៈ របស់ប្រទេស និងជាពិសេស ត្រូវធានាដល់ស្ត្រីនូវល័ក្ខខ័ណ្ឌស្មើភាព ជាមួយបុរសនូវសិទ្ធិ :*<br>*(ក) បោះឆ្នោតនៅគ្រប់ការបោះឆ្នោត និងការធ្វើប្រជាមតិសាធារណៈ និងមានសិទ្ធិឈរឈ្មោះបោះឆ្នោតសំរាប់អង្គការសាធារណៈដែលជ្រើសរើសដោយ បោះឆ្នោត ។"* ( ចំណុច ក) |
| **មាត្រា ៣៣ :** | **មាត្រា ៩ : សិទ្ធិមាន សមភាពក្នុងការទទួលសញ្ជាតិ** |

| | |
|---|---|
| "ប្រជាពលរដ្ឋខ្មែរមិនអាចត្រូវ បានដកសញ្ជាតិ ... ទៅវិញទៅមក ។" (កថាខណ្ឌ ១) | "រដ្ឋភាគីត្រូវផ្ដល់ឱ្យស្ត្រីនូវសិទ្ធិស្មើគ្នានឹងបុរស ក្នុងការទទួល ផ្លាស់ប្ដូរ ឬរក្សានូវសញ្ជាតិរបស់ខ្លួន ។ ...របស់ប្ដីឡើយ ។" (កថាខណ្ឌ ១) |
| **មាត្រា ៣៥ :**<br>"ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិចូលរួមយ៉ាងសកម្មក្នុងជីវភាពនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌របស់ ប្រទេសជាតិ ។" (កថាខណ្ឌ ១) | **មាត្រា ៧ : សិទ្ធិមាន សមភាពក្នុងវិស័យនយោបាយ និងសាធារណនៃជីវិត**<br>"រដ្ឋភាគីត្រូវប្រកាន់យកវិធានការសមស្រប ដើម្បីលុបចោលរាល់ការរើសអើង ប្រឆាំងនឹងស្ត្រីក្នុងជីវភាពនយោបាយ និងសាធារណៈ របស់ប្រទេស និងជាពិសេស ត្រូវធានាដល់ស្ត្រីនូវល័ក្ខខ័ណ្ឌស្មើភាព ជាមួយបុរសនូវសិទ្ធិ :<br>(ខ) ចូលរួមតាក់តែងគោលនយោបាយរបស់រដ្ឋ និងការអនុវត្ត គោលនយោបាយ កាន់មុខងារសាធារណៈនៅគ្រប់កម្រិត ជាន់ថ្នាក់របស់រដ្ឋាភិបាល ។ (ចំណុច ខ)<br>(គ) ចូលរួមក្នុងអង្គការ និងសមាគម មិនមែនរដ្ឋាភិបាល ដែលពាក់ព័ន្ធនឹងជីវភាព សាធារណៈ និងនយោបាយ របស់ប្រទេសជាតិ ។" (ចំណុច គ) |
| **មាត្រា ៣៦ :**<br>"ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មាន សិទ្ធិជ្រើសរើសមុខរបរ សមស្របតាមសមត្ថភាព របស់ខ្លួន | **មាត្រា ១១ : សិទ្ធិមាន សមភាពក្នុងសិទ្ធិទទួលបានការបំរើការងារ និងសិទ្ធិការងារ**<br>" រដ្ឋភាគី ត្រូវចាត់វិធានការសមស្របទាំងអស់ ដើម្បីបំបាត់ការរើសអើង ប្រឆាំងស្ត្រីក្នុងវិស័យការងារ ដើម្បីធានាដោយផ្អែកលើមូលដ្ឋានសមភាពរវាង បុរស និងស្ត្រី |

| | |
|---|---|
| តាមសេចក្ដីត្រូវការ របស់សង្គម ។" (កថាខណ្ឌ ១) | នូវសិទ្ធិដូចគ្នា និងជាពិសេស ៖ (ក) សិទ្ធិធ្វើការងារ ដែលជាសិទ្ធិមិនអាចលក់ដូរ ផ្ទេរ ឬដកហូតបាន របស់ មនុស្សជាតិគ្រប់រូប ។ (ចំណុច ក) (ខ) សិទ្ធិមានឱកាសធ្វើការងារដូចគ្នា ... ឱ្យធ្វើការងារ ដូចគ្នា ។ (ចំណុច ខ) (គ) សិទ្ធិជ្រើសរើសដោយសេរី នូវវិជ្ជាជីវៈ និងការងារ ... ជាអចិន្ត្រៃយ៍ផង ។ (ចំណុច គ) (ឃ) សិទ្ធិក្នុងការទទួលបានប្រាក់បំណាច់ស្មើគ្នា ... គុណភាពការងារ ។" (ចំណុច ឃ) |
| **មាត្រា ៣៨ ៖** "ជនគ្រប់រូបមានសិទ្ធិការពារខ្លួន តាមផ្លូវតុលាការ ។" (កថាខណ្ឌ ៨) | **មាត្រា ១៥ ៖ សិទ្ធិមានសមភាពក្នុងរឿងច្បាប់ និងស៊ីវិល** (២) "រដ្ឋភាគីត្រូវផ្ដល់ឱ្យស្ត្រីក្នុងបញ្ហារដ្ឋប្បវេណី នូវឋានៈនីត្យានុកូល ដូចគ្នានឹងបុរស និងមានឱកាសដូចគ្នា ដើម្បីប្រើឱកាសនេះ ។ ជាពិសេស រដ្ឋភាគី ត្រូវផ្ដល់ឱ្យស្ត្រី នូវសិទ្ធិស្មើគ្នាក្នុងការចុះកិច្ចសន្យា និងគ្រប់គ្រងទ្រព្យ និងត្រូវមានការប្រព្រឹត្ដិ មកលើស្ត្រីដូចគ្នា ក្នុងគ្រប់ដំណាក់កាលនៃនីតិវិធីរបស់តុលាការ និងសាលាជំរះក្ដី ។" (ចំណុច ទី ២) |
| **មាត្រា ៤០ ៖** "សេរីភាព ក្នុងការធ្វើដំណើរ ឆ្ងាយជិត និងតាំងទីលំនៅក្នុងស្ថានភាពស្របច្បាប់របស់ប្រជាពលរដ្ឋ ត្រូវបានគោរព ។" (កថាខណ្ឌ ១) | **មាត្រា ១៥ ៖ សិទ្ធិមានសមភាពក្នុងរឿងច្បាប់ និងស៊ីវិល** (៤) "រដ្ឋភាគីត្រូវឱ្យបុរសនិងស្ត្រីមានសិទ្ធិដូចគ្នាចំពោះមុខច្បាប់ ដែលទាក់ទង ដល់សិទ្ធិធ្វើដំណើររបស់បុគ្គល និងសេរីភាពជ្រើសរើសទិវេសនដ្ឋាន និងលំនៅដ្ឋាន ។" (ចំណុច ទី ៤) |

| | |
|---|---|
| **មាត្រា ៤១ :**<br>" ប្រជាពលរដ្ឋខ្មែរមាន សេរីភាពខាងការបញ្ចេញ មតិរបស់ខ្លួន សេរីភាពខាង សារព័ត៌មាន សេរីភាពខាង ការបោះពុម្ព ផ្សាយ សេរីភាពក្នុងការប្រជុំ ។ ជនណា ... សន្តិសុខជាតិបាន ឡើយ ។" (កថាខណ្ឌ ១) | **មាត្រា ៧ : សិទ្ធិមាន សមភាពក្នុងវិស័យនយោបាយ និងសាធារណនៃជីវិត**<br>" រដ្ឋភាគីត្រូវប្រកាន់យកវិធានការសមស្រប...ធានាដល់ស្ត្រីនូវ ល័ក្ខខ័ណ្ឌស្មើភាពជាមួយបុរស នូវសិទ្ធិ :<br>(គ) ចូលរួមក្នុងអង្គការ និងសមាគម ក្រៅរដ្ឋាភិបាល ដែលពាក់ព័ន្ធនឹងជីវភាព សាធារណៈ និងនយោបាយរបស់ ប្រទេសជាតិ ។" (ចំណុច គ)<br>**មាត្រា ១៣ : ជីវភាពសេដ្ឋកិច្ច កីឡា និងវប្បធមិ**<br>"រដ្ឋភាគី ត្រូវចាត់វិធានការសមស្រប ... ដើម្បីធានា ដោយផ្អែកលើមូលដ្ឋាន សមភាពរវាងបុរសនិង ស្ត្រីនូវសិទ្ធិ ដូចគ្នា ជាពិសេស :<br>(គ) សិទ្ធិចូលរួមក្នុងសកម្មភាពកំសាន្ត កីឡា និងគ្រប់ទិដ្ឋភាព នៃជីវភាពវប្បធមិ ។" (ចំណុច គ) |
| **មាត្រា ៤៣ :**<br>"ប្រជាពលរដ្ឋខ្មែរទាំងពីរ ភេទមានសិទ្ធិពេញទីខាង ជំនឿ ។ "(កថាខណ្ឌ ១) | **មាត្រា ១៣ : វិស័យសេដ្ឋកិច្ច កីឡា និងវប្បធមិនៃជីវិត**<br>"រដ្ឋភាគី ត្រូវចាត់វិធានការសមស្រប ដើម្បីបំបាត់ ការរើសអើង ប្រឆាំងនឹងស្ត្រី ក្នុងវិស័យជីវភាព សេដ្ឋកិច្ច និងសង្គមផ្សេងទៀត ដើម្បី ធានា ដោយផ្អែកលើ មូលដ្ឋាន សមភាពរវាងបុរស និងស្ត្រី នូវសិទ្ធិដូចគ្នា ជាពិសេស :<br>(គ) សិទ្ធិ ចូលរួមក្នុងសកម្មភាព កំសាន្ត កីឡា និងគ្រប់ ទិដ្ឋភាពនៃជីវភាពវប្បធមិ ។"(ចំណុច គ) |

| | |
|---|---|
| **មាត្រា ៤៤ :**<br>*"ជនណាក៏ដោយ ទោះជាបុគ្គលក្តី ជាសមូហភាពក្តី មានសិទ្ធិ ជាម្ចាស់កម្មសិទ្ធិ ។ មានតែ រូបវន្តបុគ្គល... សិទ្ធិលើដីធ្លី ។"*<br>(កថាខណ្ឌ ១) | **មាត្រា ១៥ : សិទ្ធិមាន សមភាពក្នុងរឿងច្បាប់ និងស៊ីវិល**<br>២) *"រដ្ឋភាគីត្រូវផ្តល់ឱ្យស្ត្រីក្នុងបញ្ហារដ្ឋប្បវេណី នូវឋានៈនីត្យានុកូល ដូចគ្នា នឹងបុរស និងមានឱកាសដូចគ្នាដើម្បីប្រើឱកាសនេះ ។ ជាពិសេស រដ្ឋភាគីត្រូវផ្តល់ឱ្យស្ត្រីនូវសិទ្ធិស្មើគ្នាក្នុងការចុះកិច្ចសន្យា និងការគ្រប់គ្រងទ្រព្យ និងត្រូវឱ្យមានការ ប្រព្រឹត្តិមកលើស្ត្រីដូចគ្នា ក្នុងគ្រប់ដំណាក់កាលនៃនីតិវិធីរបស់តុលាការ និងសាលា ជំរះក្តី ។"*<br>(ចំណុច ទី ២)<br>**មាត្រា ១៦ : សិទ្ធិមាន សមភាពក្នុងច្បាប់គ្រួសារ**<br>១. *"រដ្ឋភាគីត្រូវចាត់វិធានការ...ត្រូវធានាឱ្យស្ត្រីនូវ :*<br>ជ) *សិទ្ធិដូចគ្នាសម្រាប់ទាំងពីរនាក់ប្តីប្រពន្ធចំពោះកម្មសិទ្ធិ ការទិញ ការ ចាត់ចែង ការគ្រប់គ្រង ការអាស្រ័យផល និងការប្រគល់ទ្រព្យសម្បត្តិ ទោះដោយ មិនគិតថ្លៃក្តី ឬគិតថ្លៃក្តី ។"* (ផ្នែកទី ១ ចំណុច ជ) |
| **មាត្រា ៤៥ :**<br>*"ការរើសអើងគ្រប់ប្រភេទប្រឆាំងនឹងស្ត្រីភេទ ត្រូវបំបាត់ ចោល ។"*<br>(កថាខណ្ឌ ១) | **មាត្រា ២: កាតព្វកិច្ចរដ្ឋ**<br>ជាទូទៅ **មាត្រា ២** លើកឡើងពីកាតព្វកិច្ចរបស់រដ្ឋអនុលោមតាមអនុសញ្ញា និង គោលនយោបាយ ដែលអនុញ្ញាតឱ្យមានការលុបបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រី ។ ឈរលើមូលដ្ឋាននៃការលុបបំបាត់ភាពរើសអើង រដ្ឋត្រូវធ្វើការពិនិត្យឡើងវិញនូវច្បាប់ រដ្ឋប្បវេណី ច្បាប់ព្រហ្មទណ្ឌ និងច្បាប់ការងារ ។<br>**មាត្រា៧-កថាខណ្ឌ ១** |

| | |
|---|---|
| | រដ្ឋភាគីត្រូវប្រកាន់យកវិធានការសមស្រប ដើម្បីលុបចោលរាល់ ការរើសអើង ប្រឆាំងនឹងស្ត្រីក្នុងជីវភាពនយោបាយ និងសាធារណៈ របស់ប្រទេស និងជាពិសេស ត្រូវធានាដល់ស្ត្រីនូវ ល័ក្ខខ័ណ្ឌស្មើភាព ជាមួយបុរសនូវសិទ្ធិ<br>**មាត្រា១០ -កថាខណ្ឌ ១**<br>– សិទ្ធិស្មើគ្នាជាមួយបុរស ក្នុងវិស័យនៃការអប់រំ " រដ្ឋភាគីត្រូវ ប្រកាន់វិធានការ ... ដើម្បីធានាឱ្យស្ត្រីមានសិទ្ធិស្មើគ្នានឹង បុរសក្នុងវិស័យ អប់រំ និងជាពិសេស ដើម្បីធានាដល់ស្ត្រី ដោយផ្អែកលើមូលដ្ឋាននៃសមភាព រវាងបុរសនឹងស្ត្រីនូវ..."<br>**មាត្រា១១-កថាខណ្ឌ ១**<br>– ការទទួលបានការងារ ក្នុងគោលបំណងធានាអំពីមូលដ្ឋាននៃសមភាពរវាង បុរស-ស្ត្រី " រដ្ឋភាគី ត្រូវចាត់វិធានការសមស្របទាំងអស់ ដើម្បី បំបាត់ការរើសអើងប្រឆាំងស្ត្រីក្នុងវិស័យការងារ ដោយផ្អែកលើមូលដ្ឋាន នៃសមភាពរវាងបុរសនឹងស្ត្រី នូវសិទ្ធិដូចគ្នា និងជាពិសេស :..."<br>**មាត្រា១២-កថាខណ្ឌ ១**<br>– សិទ្ធិស្មើគ្នារវាងបុរស-ស្ត្រី ក្នុងការទទួលបានសេវាសុខភាពរួមមានការ និយាយដល់ផែនការគ្រួសារ " រដ្ឋភាគីត្រូវចាត់វិធានការសមស្របទាំងអស់ ដើម្បីបំបាត់ការរើសអើងប្រឆាំង ស្ត្រីក្នុងវិស័យថែទាំសុខភាព ដើម្បីធានា ដោយ |

| | |
|---|---|
| | *ផ្អែកលើ មូលដ្ឋាននៃសមភាពរវាងបុរសនឹងស្ត្រីនូវសិទ្ធិ ទទួលបានសេវា សុខាភិបាល រួមមានមធ្យោបាយទាក់ទង នឹងផែនការគ្រួសារផង ។"*<br>**មាត្រា១៤-កថាខណ្ឌ ២**<br>– សិទ្ធិស្មើគ្នារវាងបុរស-ស្ត្រី ក្នុងការទទួលបាននូវផល ប្រយោជន៍ពីការ អភិវឌ្ឍជនបទ " *រដ្ឋភាគី ត្រូវប្រកាន់ វិធានការ...ដើម្បីធានា ដោយផ្អែកលើមូលដ្ឋានសមភាព រវាងបុរសនឹងស្ត្រីនូវការចូលរួមរបស់ស្ត្រីក្នុងការ អភិវឌ្ឍន៍ ជនបទ និងទទួលបានអត្ថប្រយោជន៍ពី ការអភិវឌ្ឍន៍ ជនបទ..."*<br>**មាត្រា១៦-កថាខណ្ឌ ១**<br>– រាល់រឿងរ៉ាវទាំងឡាយទាក់ទងនឹងទំនាក់ទំនងអាពាហ៍ ពិពាហ៍ និងគ្រួសារ ពិសេសនោះត្រូវមានការធានាអំពី មូលដ្ឋាន នៃសមភាពរវាងបុរស និងស្ត្រី " *រដ្ឋភាគីត្រូវ ចាត់វិធានការ សមស្របទាំងអស់ ដើម្បីបំបាត់ការរើសអើង ប្រឆាំងស្ត្រីលើ រាល់បញ្ហាដែលទាក់នឹងអាពាហ៍ពិពាហ៍ និងទំនាក់ទំនងគ្រួសារ និងជាពិសេស ដោយផ្អែកលើ មូលដ្ឋាន នៃសមភាព រវាងបុរស និងស្ត្រីត្រូវ ធានា ..."* |
| **មាត្រា ៦៥ :**<br>សិទ្ធិស្មើគ្នា ក្នុងការអប់រំសម្រាប់ ប្រជាពលរដ្ឋគ្រប់រូប ត្រូវបាន | **មាត្រា ១០ : សិទ្ធិមានសមភាពក្នុងការអប់រំ**<br>*" រដ្ឋភាគីត្រូវប្រកាន់យកវិធានការសមស្របទាំងអស់ ដើម្បី លុបបំបាត់ការរើស អើងប្រឆាំងនឹងស្ត្រី ដើម្បីធានាឱ្យស្ត្រីមាន* |

| | |
|---|---|
| ទទួលស្គាល់ ។<br>" រដ្ឋត្រូវការពារ និងលើកស្ទួយ សិទ្ធិរបស់ប្រជាពលរដ្ឋ ក្នុងការទទួលការអប់រំ ប្រកបដោយគុណភាព ... ដើម្បីឱ្យការ អប់រំនេះបាន ទៅដល់ប្រជាពល រដ្ឋគ្រប់ រូប ។ "<br>(មាត្រា៦៥-កថាខណ្ឌ១) | *សិទ្ធិស្មើគ្នានឹងបុរស ក្នុងវិស័យ អប់រំ..."*។ ( កថាខណ្ឌ ១ ) |
| **មាត្រា ៧២ :**<br>*"សុខភាពរបស់ប្រជាពលរដ្ឋ ត្រូវបានធានា ។ រដ្ឋយកចិត្តទុកដាក់ ...និងមន្ទីរសម្ភព សាធារណៈ ។ "*<br>(មាត្រា៧២-កថាខណ្ឌ ១ ) | **មាត្រា ១២ : សិទ្ធិមានសមភាពក្នុងការទទួលបានសេវាសុខភាព**<br>*" រដ្ឋភាគី ត្រូវប្រកាន់យកវិធានការសមស្របទាំងអស់ ដើម្បីលុបបំបាត់ការរើស អើងប្រឆាំងនឹងស្ត្រី ដើម្បីធានា ដោយផ្អែកលើ មូលដ្ឋានសមភាព រវាងបុរស និងស្ត្រីនូវសិទ្ធិ ទទួលសេវា សុខាភិបាល រួមមានមធ្យោបាយទាក់ទងនឹង ផែនការ គ្រួសារផង ។ "* ( កថាខណ្ឌ ១ ) |



# បទប្បញ្ញត្តិនានាសម្រាប់សិទ្ធិស្ត្រី ៖ ច្បាប់នៃព្រះរាជាណាចក្រកម្ពុជា

## ច្បាប់ការងារកម្ពុជា (១៩៩៧)



ច្បាប់ការងារ បានអនុម័តក្នុងឆ្នាំ ១៩៩៧ ។ ថ្វីដ្បិតតែមានបញ្ហា និងចន្លោះប្រហោងខ្លះៗ នៅក្នុងច្បាប់នេះ នីតិកម្មមួយនេះ បង្កើតបានជា**ទម្លាប់មុន** សម្រាប់នីតិកម្មក្រោយៗមកទៀត ។ច្បាប់នេះ បានទទួលស្គាល់ការយកចិត្តទុកដាក់ទាំងឡាយ និងយេនឌ័រជាក់ ដោយឡែកៗ ហើយបង្កឱ្យបាននូវសិទ្ធិដ៏សេរីសម្រាប់ស្ត្រីក្នុងវិស័យការបម្រើការងារ ។

ដោយឡែកច្បាប់ការងារឆ្នាំ ១៩៩៧ បញ្ចូលមាត្រា១១ នៃអនុសញ្ញាស៊ី-ដ ដែលថ្លែងថា ស្ត្រីទាំងឡាយមានសិទ្ធិក្នុងវិស័យបំរើការងារដូចគ្នា និងបុរសដែរ គេក៏ត្រូវមានការឈប់សំរាកមាតុភាព និងការការពារគ្រោះថ្នាក់ពីការងារ ក្នុងពេលមានផ្ទៃពោះ ។

ក្នុងអង្គច្បាប់ មានមាត្រាគន្លឹះបី ដែលមានលក្ខខណ្ឌពិសេសចែងច្បាស់ៗ ដើម្បីការពារសិទ្ធិរបស់ស្ត្រី ។

## មាត្រា ១០៦ :

*"ចំពោះការងារ ដែលមានល័ក្ខខ័ណ្ឌដូចគ្នា ភាពប៉ិនប្រសប់ខាង វិជ្ជាជីវៈនិងផលដែលធ្វើបានស្មើគ្នា ប្រាក់ឈ្នួលត្រូវឱ្យស្មើគ្នាដល់កម្មករនិងនិយោជិកទាំងអស់ត្រូវស្ថិតនៅក្រោមឱវាទនៃច្បាប់នេះ ទោះមានដើមកំណើតភេទ ឬអាយុប៉ុន្មានក៏ដោយ "* ។

## មាត្រា ១៨២ :

*" ... ត្រូវហាមឃាត់មិនឱ្យនិយោជកបញ្ឈប់ស្ត្រី ពីការងារនៅពេលឈប់ឆ្លងទន្លេ ឬនៅថ្ងៃចុងក្រោយក្នុងពេលឈប់សំរាលកូន ទោះឱ្យដំណឹងក្នុងពេលឈប់សំរាកក៏ដោយ"* ។

## មាត្រា ២១៩ :

*"កាលបើចំការណាមួយប្រើកម្មករ និយោជិកជាប់លាប់ជាភេទស្រី មានចំនួនពីមួយរយនាក់ឡើងទៅ អធិការការងារអាចចាត់បង្គាប់ឱ្យនិយោជក សង់ រៀបចំ ឬ ថែទាំ ទារកដ្ឋានមួយនៅជិតគេស្នាក់នៅ តាមការណែនាំពីក្រុមអនាម័យ និងអភិបាលខេត្ត-ក្រុង ...* ។

## ច្បាប់អាពាហ៍ពិពាហ៍ និង គ្រួសារ (១៩៨៩)

ច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារត្រូវបានអនុម័ត ដោយរដ្ឋសភាជាតិ ពីថ្ងៃ១៧ ខែកក្កដា ១៩៨៩ ក្នុងកិច្ចប្រជុំសាមញ្ញលើកទី ១៧ នៃអាណត្តិទី ១ របស់រដ្ឋសភាជាតិនៃរដ្ឋកម្ពុជា ។ ច្បាប់នេះលាតត្រដាងឱ្យឃើញសិទ្ធិ និងការទទួលខុសត្រូវរបស់ឯកត្តជនដែលរៀបការ លែងលះប្តីប្រពន្ធ ឬចិញ្ចឹមកូន ។

### មាត្រា ១ បានចែងថា ៖

*"ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ដោយផ្អែកលើមាត្រា៧ និងមាត្រា៨ នៃរដ្ឋធម្មនុញ្ញនៃរដ្ឋកម្ពុជា មានគោលដៅដាក់បទបញ្ញា និងការពារការរៀបអាពាហ៍ពិពាហ៍ និងក្នុងជីវភាពគ្រួសារ ធានាសមភាព រវាងសហព័ទ្ធក្នុងអាពាហ៍ពិពាហ៍ និងក្នុងគ្រួសារ ពង្រឹងការទទួលខុសត្រូវរបស់ឪពុកម្តាយ ក្នុងការចិញ្ចឹម ថែរក្សាកូន និងជំរុញការបណ្តុះបណ្តាលសីលធម៌ និងការអប់រំកូន ដើម្បីឱ្យទៅជាពលរដ្ឋល្អ មានមនសិការ ស្នេហាជាតិ ស្រលាញ់ការងារ មានសម្បជញ្ញៈទទួលខុសត្រូវចំពោះសង្គម ។"*

ច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារត្រូវបានអនុម័តក្នុងសម័យមុនរដ្ឋធម្មនុញ្ញ (១៩៩៣) ។ មាត្រាជាច្រើនមិនបានបញ្ចូលគោលការណ៍ទាំងឡាយរបស់អនុសញ្ញាស៊ី-ដ ដែលត្រូវបានទទួលស្គាល់ដោយរដ្ឋធម្មនុញ្ញ ។ ជាឧទាហរណ៍ មាត្រា ៩ ថ្លែងថា ស្ត្រីណាម្នាក់ដែលប្រាថ្នារៀបការឡើងវិញត្រូវរងចាំ ៣០០ថ្ងៃក្រោយថ្ងៃបញ្ចប់អាពាហ៍ពិពាហ៍មុន នៅពេលដែលគ្មានលក្ខខណ្ឌបែបនេះអនុវត្តទៅលើបុរសៗឡើយ ។ សំណាងល្អសេចក្តីព្រាងក្រមរដ្ឋប្បវេណីថ្មី នឹងត្រូវបានអនុម័តក្នុងពេលឆាប់ៗ ដែលនឹងដកបទប្បញ្ញត្តិបែបនោះចេញ ។

## អាជ្ញាធរអន្តរកាលរបស់អង្គការសហប្រជាជាតិប្រចាំប្រទេសកម្ពុជា UNTAC (១៩៩២) :

### នីតិវិធីព្រហ្មទណ្ឌ

អំពើហឹង្សាប្រឆាំងស្ត្រី ជាបញ្ហាធ្ងន់ធ្ងរនៅកម្ពុជា ហើយ**ច្បាប់របស់អាជ្ញាធរបណ្ដោះអាសន្ននៃអង្គការសហប្រជាជាតិនៅកម្ពុជា** (**ហៅថាអ៊ុនតាក់**)ដាក់ទោសដល់សណ្ឋានខ្លះៗ នៃអំពើហឹង្សាប្រឆាំងនឹងស្ត្រី ។

### មាត្រា ៣៣ : បទរំលោភសេពសន្ថវ

*១: ជនណាក៏ដោយដែលរំលោភសេពសន្ថវៈ ឬ ប៉ុនប៉ងសំលោភសេពសន្ថវៈលើជនម្នាក់ទៀត ទោះភេទដូចគ្នា ឬមិនដូចគ្នាក៏ដោយ ត្រូវមានទោសពីបទសេពសន្ថវៈ ហើយផ្ដន្ទាទោសដាក់គុកជាបទឧក្រិដ្ឋពី ៥ឆ្នាំ ទៅ ១០ឆ្នាំ ។*

*២: បទរំលោភសេពសន្ថវៈ គឺគ្រប់អំពើបញ្ចូលអង្គជាតិដោយ ឃោរឃៅ ដោយបង្ខំ ឬដោយមិនដឹងខ្លួនជាមុន ។ ប្រសិនបើការរំលោភសេពសន្ថវៈបានត្រូវប្រព្រឹត្តឡើង ដោយការគំរាមកំហែងនឹងអាវុធទៅលើស្ត្រីមានផ្ទៃពោះ លើជនមានជំងឺ ឬ ជនមានសតិវិបល្លាស ឬជនពិការរាងកាយ ឬធ្វើឡើងដោយមានអ្នកប្រព្រឹត្តពីរនាក់ ឬច្រើននាក់ ឬដោយមានអ្នកសមគំនិត ឬបើការសេពសន្ថវៈនោះត្រូវប្រព្រឹត្តឡើង ដោយជនដែលមានអំណាចលើអ្នករងគ្រោះទណ្ឌកម្មដែលត្រូវអនុវត្តដាក់គុកជាបទឧក្រិដ្ឋពី ១០ឆ្នាំ ទៅ ១៥ឆ្នាំ ។*

### មាត្រា ៤១ : អំពើបង្ករបួសដោយចេតនា

១: ជនណាវាយតប់ បណ្តាលអោយមានរបួស ដែលនាំអោយពិការជាអចិន្ត្រៃយ៍ ឬពិការបណ្តោះអាសន្ន ក្នុងរយៈពេលលើសពី ៦ខែ ដោយចេតនា ត្រូវមានទោសពីបទបង្ករបួសដោយចេតនា ហើយត្រូវផ្តន្ទាទោសដាក់គុកពី ១ឆ្នាំ ទៅ ៥ឆ្នាំ ។

២: បើពិការភាពបណ្តោះអាសន្ននោះពិចជាង ៦ខែ ត្រូវផ្តន្ទាទោសដាក់គុកជននោះពី ៦ខែ ទៅដល់ ២ឆ្នាំ ។

៣: បើគ្មានពិការភាពទេ ទោសដែលត្រូវកំណត់ផ្តន្ទាគឺដាក់គុកពី ២ខែ ទៅ ១ឆ្នាំ ។

៤: បើការវាយតប់នោះ ធ្វើឡើងដោយប្រើអាវុធប្រភេទណាមួយ ក៏រិតទោសត្រូវទ្វេមួយជាពីរ ។

## មាត្រា ៤២ : អំពើបៀតបៀនដល់កេរ្តិ៍ខ្មាស់

*១: ជនណាដែលបៀតបៀនដល់កេរ្តិ៍ខ្មាស់នៃជនណាម្នាក់ទៀត ដែលមានភេទដូចគ្នា ឬមិនដូចគ្នាដោយប្រព្រឹត្តទៅលើជននោះ តាមការស្ទាបអង្អែល ឬអំពើផ្សេងទៀតទាក់ទងនឹងរឿងភេទ ប៉ុន្តែពុំបានដល់ទីជម្រៅ ត្រូវមានទោសពីបទបៀតបៀនដល់កេរ្តិ៍ខ្មាស់ ហើយត្រូវផ្តន្ទាទោសដាក់ គុកពី ១ឆ្នាំ ទៅ ៣ឆ្នាំ ។*

*២: បើការបៀតបៀនដល់កេរ្តិ៍ខ្មាស់នោះ ធ្វើឡើងដោយការបន្លំ ដោយអំពើហិង្សា ដោយការគំរាមកំហែង បើអ្នករងគ្រោះមានអាយុតិចជាង ១៦ឆ្នាំ ឬ អ្នកប្រព្រឹត្តអំពើនោះ ជាអ្នកមានអំណាចលើជនរងគ្រោះ ក៏រិតផ្តន្ទាទោសត្រូវទ្វេមួយជាពីរ ។*

*៣: នឹងត្រូវផ្តន្ទាទោសដាក់គុកពី ២ឆ្នាំ ទៅ ៦ឆ្នាំដែរ ចំពោះជនណាដែលបានល្បួង អូសទាញ ឬ បង្វែងគំនិតអនីតិជនដើម្បីធ្វើពេស្យាចារ ឬធ្វើអាជីវកម្មពេស្យាចារលើអនីតិជន ទោះបីមានការព្រមព្រៀងក៏ដោយ ។*

រីឯចំពោះឧក្រិដ្ឋកម្មរំលោភផ្លូវភេទវិញ ការដាក់ទោសដល់អ្នកប្រព្រឹត្តបទល្មើសត្រូវបានតម្លើងឱ្យធ្ងន់នៅក្នុងច្បាប់ "**ស្តីពីករណីធ្ងន់ធ្ងរនៃបទឧក្រិដ្ឋ** " (វិសោធនកម្មនៃច្បាប់អ៊ុនតាក់) មានដូចតទៅ :

## មាត្រា ៥ :

*១: ជនណាក៏ដោយដែលរំលោភសេពសន្ថវៈ ឬ ប៉ុនប៉ងសំលោភសេពសន្ថវៈលើជនម្នាក់ទៀត ទោះភេទដូចគ្នា ឬមិនដូចគ្នាក៏ដោយ ត្រូវមានទោសពីបទសេពសន្ថវៈ ហើយផ្តន្ទាទោសដាក់គុកជាបទឧក្រិដ្ឋពី ១០ឆ្នាំ ទៅ ១៥ឆ្នាំ ។*

*២: បទរំលោភសេពសន្ថវៈ គឺគ្រប់អំពើបញ្ចូលអង្គជាតិដោយ ឃោរឃៅ ដោយបង្ខំ ឬ ដោយមិនដឹងខ្លួនជាមុន ។ ប្រសិនបើការរំលោភសេពសន្ថវៈបានត្រូវប្រព្រឹត្តឡើង*

*ដោយការគំរាមកំហែងនឹងអាវុធទៅលើស្ត្រីមានផ្ទៃពោះ លើជនមានជំងឺ ឬ ជនមានសតិវិបល្លាស ឬ ជនពិការរាងកាយ ឬអនីតិជនអាយុតិចជាង ១៨ឆ្នាំ ធ្វើឡើងដោយមានអ្នកប្រព្រឹត្តពីរនាក់ ឬច្រើននាក់ ឬដោយមានអ្នកសមគំនិត ឬបើការសេពសន្ថវៈនោះត្រូវប្រព្រឹត្តឡើងដោយជនដែលមានអំណាចលើអ្នករងគ្រោះ ទណ្ឌកម្មដែលត្រូវអនុវត្តដាក់គុកជាបទឧក្រិដ្ឋពី ១៥ឆ្នាំ ទៅ ២០ឆ្នាំ ។*

ក៏ប៉ុន្តែច្បាប់នេះ នៅតែមិនគ្រប់គ្រាន់ដើម្បីផ្តល់ការការពារស័ក្តិសិទ្ធសម្រាប់សិទ្ធិស្ត្រី ឱ្យរួចផុតពីអំពើហឹង្សា ដូច្នេះចាំបាច់ត្រូវតែមានច្បាប់ដ៏ទៃទៀត ។

## ការបង្ក្រាបអំពើពង្រត់និងលក់ដូរមនុស្ស និងអំពើធ្វើអាជីវកម្មលើមនុស្ស (១៩៩៦)

ក្នុងសេចក្តីប៉ងដើម្បីការពារស្ត្រីពីការជួញដូរសម្រាប់ការធ្វើអាជីវកម្មផ្លូវភេទ **ច្បាប់ស្តីពី ការបង្ក្រាបអំពើពង្រត់និងលក់ដូរមនុស្ស និងអំពើធ្វើអាជីវកម្មលើមនុស្ស** ត្រូវបានអនុម័តក្នុងឆ្នាំ ១៩៩៦ ។ ច្បាប់នេះគ្របដណ្តប់មិនត្រឹមតែលើការលក់ដូរប៉ុណ្ណោះទេ ថែមទាំងទៅលើការហាមឃាត់ **អ្នកពពាយនាយលក់ផ្លូវភេទ អំពើអាសអាភាស ឬអនាចារ** ផងដែរ ។

### មាត្រា ៣ :

*ជនណាអូសទាញមនុស្ស ទោះបីជាស្រីឬប្រុស អនីតិជនឬនីតិជន មានសញ្ជាតិអ្វីក៏ដោយ ដោយវិធីលួងលោម សន្យាឱ្យប្រាក់កាសឬគ្រឿងអលង្ការឬតាមវិធីណាក៏ដោយ ទោះបីសាមីខ្លួនសុខចិត្តឬមិនសុខចិត្ត ដោយវិធីបង្ខិតបង្ខំ គំរាមកំហែងឬប្រើថ្នាំសណ្តំស្មារតីនិងសតិអារម្មណ៍*

ដើម្បីពង្រត់យកទៅលក់ឬយកទៅធ្វើពេស្យាចារ ជននោះត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ឆ្នាំ ដល់ ១៥ឆ្នាំ ។ បើជនរងគ្រោះជាអនីតិជនអាយុតិចជាង ១៥ឆ្នាំ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១៥ឆ្នាំ ដល់ ២០ឆ្នាំ ។

អ្នកសមគំនិត អ្នកលក់ អ្នកទទួលទិញឬទទួលយក ត្រូវមានទោសដូចអ្នកប្រព្រឹត្តដែរ ។

ត្រូវចាត់ទុកជាអ្នកសមគំនិតដែរ អ្នកដែលផ្តល់ប្រាក់ឬផ្តល់មធ្យោបាយផ្សេងៗសម្រាប់ប្រព្រឹត្តបទល្មើស ។

មធ្យោបាយដឹកជញ្ជូន សម្ភារៈនិងទ្រព្យសម្បត្តិប្រើប្រាស់ ក្នុងពេលប្រព្រឹត្តបទល្មើសត្រូវរឹបអូសជាសម្បត្តិរដ្ឋ ។

## មាត្រា ៧ :

ជនណាដែលបើកកន្លែងសម្រាប់ប្រព្រឹត្តអំពើអនាចារឬអំពើអាសអាភាសផ្សេងៗ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ឆ្នាំ ដល់ ៥ឆ្នាំ និងពិន័យជាប្រាក់ពី ៥.០០០.០០០រៀល " ប្រាំលានរៀល" ដល់ ៣០.០០០.០០០រៀល " សាមសិបលានរៀល " ។ ក្នុងករណីមិនរាងចាល ត្រូវផ្តន្ទាទោសទ្វេជាពីរ ។

## មាត្រា ៨ :

ជនណាដែលបានប្រព្រឹត្តអនាចារ លើអនីតិជនអាយុក្រោម ១៥ឆ្នាំ ទោះបីអនីតិជននោះស្ម័គ្រចិត្តក្តីឬដោយទិញក្មេងនោះពីអ្នកដទៃក្តីឬទិញពីជនជាមេពេស្យាក្តី ជននោះត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ឆ្នាំ ដល់ ២០ឆ្នាំ ។ ក្នុងករណីមិនរាងចាល ត្រូវយកអតិបរមានៃទោសមកអនុវត្ត ។

*តុលាការអាចយកអនុទោសត្រង់ស្ថានបន្ថយសិទ្ធិស៊ីវិល និងហាមស្នាក់អាស្រ័យមកផ្តន្ទា បន្ថែមលើមូលទោសខាងលើនោះបាន ។*

ច្បាប់នេះត្រូវបានប្រើក្នុងតុលាការ ដើម្បីយកអ្នកប្រព្រឹត្តបទល្មើសទៅវិនិច្ឆ័យ និងដាក់ទោសពីឧក្រិដ្ឋកម្មទាំងឡាយដែលមានកំណត់នៅក្នុងច្បាប់នេះ ។ ក៏ប៉ុន្តែច្បាប់នេះនៅមានចន្លោះប្រហោងច្រើន ។ ជាឧទាហរណ៍ គ្មាននិយមន័យសម្រាប់ វាក្យស័ព្ទគន្លឹះនានា គ្មាននិយមន័យសម្រាប់វាក្យស័ព្ទ ការលក់ដូរ ។ ពង្រាងច្បាប់ដើម្បីជំនួសច្បាប់បច្ចុប្បន្ន ត្រូវបានទទួលការពិភាក្សាអស់រយៈជិតមួយទស្សវត្តមកហើយ ហើយនៅតែមិនទាន់ត្រូវបានបញ្ជូនទៅសភាជាតិនៅឡើយទេ ។

## ច្បាប់ទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និង កិច្ចការពារជនរងគ្រោះ

ក្នុងឆ្នាំ ២០០៥ **ច្បាប់ទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និង កិច្ចការពារជនរងគ្រោះ** ត្រូវបានអនុម័ត ។ ច្បាប់នេះណែនាំឱ្យស្គាល់យន្តការណ៍ថ្មីៗ សម្រាប់អ្នករងគ្រោះពីអំពើហឹង្សាក្នុងគ្រួសារ ។

### មាត្រា ១ បានចែងថា ៖

*" ច្បាប់នេះមានគោលបំណងទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ ការពារជនរងគ្រោះនិងពង្រឹងវប្បធម៌អហិង្សា និងភាពសុខដុមរមនាក្នុងគ្រួសារក្នុងសង្គមនៅព្រះរាជាណាចក្រកម្ពុជា ។ ច្បាប់នេះមានទិសដៅបង្កើតយន្តការនីត្យានុកូលភាព ដើម្បីទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ ការពារជនរងគ្រោះ និងថែរក្សាភាពសុខដុមរមនាក្នុងគ្រួសារ តាមទំនៀមទម្លាប់ និងប្រពៃណីល្អរបស់ជាតិ ។ ស្របតាមមាត្រា៤៥ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដោយបំពេញបន្ថែមលើបទដ្ឋានគតិយុត្តជាធរមាន ។ "*

ច្បាប់នេះត្រូវបានអនុម័ត បន្ទាប់ពីមានការជជែកដេញដោលគ្នាអស់រយៈមួយទសវត្សរ៍ក្នុងបណ្ដាសង្គមស៊ីវិល រួមទាំងនៅរដ្ឋសភាផង ។ ការអនុម័តច្បាប់នេះត្រូវបានទទួលស្គាល់ថាជាជំហានមួយដ៏សំខាន់ក្នុការការពារស្ត្រី ថ្វីត្បិតតែច្បាប់នេះមិនមែនគ្រាន់តែ ការពារស្ត្រីពីអំពើហឹង្សាប៉ុណ្ណោះទេ កុមារក៏ត្រូវបានការពារ សូម្បីតែបុរសក៏ត្រូវបានការពារផងដែរ ។ ក៏ប៉ុន្តែការអនុវត្តនៅមានកំរិតនៅឡើយ ដូច្នេះហើយការប្រឹងប្រែងបន្ថែមទៀត នៅតែត្រូវការក្នុងបណ្ដាមន្ត្រីអនុវត្តច្បាប់ អាជ្ញាធរដែនដី និងអង្គការសង្គមស៊ីវិលនានា ។

## ហេតុអ្វីបានជា ការចេះដឹងពីបទប្បញ្ញត្តិទាំងអស់នោះ មានសារៈសំខាន់?

នៅពេលដែលអ្នកធ្វើខ្លួនអ្នកឱ្យស្គាល់ច្បាស់ពីមាតិកានៃច្បាប់ជាតិកម្ពុជាទាំងអស់អ្នកអាចឃើញថា មានចន្លោះ ឬក៏ជួនកាលសិទ្ធិមួយចំនួនមិនត្រូវបានលើកយកមកស្ដី ក្នុងករណីខ្លះ ។ នេះគឺមកពីហេតុថា កាលណាសិទ្ធិទាំងឡាយណាមិនត្រូវបានលើក យកមកការពារជាក់លាក់ក្នុងច្បាប់នោះ មិនមែនមានន័យថាសិទ្ធិនោះ ត្រូវបានគេបដិសេធនោះទេ ។ សេចក្ដីបំណងរបស់ច្បាប់គឺមិនមែនឱ្យសិទ្ធិទេ តែដាក់របៀបលើឥរិយាបថរវាងសមាជិកក្នុងសង្គម ។ បើកាលណាច្បាប់នៅស្ងៀមមិនស្ដី ចំពោះរឿងអ្វីមួយ "ភាពស្ងៀមមិនស្ដី " នោះមិនធ្វើ ឱ្យរឿងនោះខុសច្បាប់ទេ ។ ឧទាហរណ៍ មិនមានច្បាប់ណាមួយ អនុញ្ញាតឱ្យប្រជាពលរដ្ឋទុក សត្វស្វានៅក្នុងផ្ទះឡើយ តែក៏គ្មានការហាមឃាត់ការទុកនោះដែរ ។ ឧទាហរណ៍មួយទៀត គឺថា អ្នកមិនត្រូវការមានច្បាប់អនុញ្ញាតឱ្យមានសេរីភាពក្នុងការនិយាយស្ដី ដើម្បីបានការអនុញ្ញាតឱ្យនិយាយដោយសេរីនោះទេ ។ យ៉ាងនេះហើយបានថា **សិទ្ធិដែលមានចំពោះពលរដ្ឋ គឺជារបស់ពលរដ្ឋ ។**

មានភាពជឿនលឿនគួរឱ្យកត់សម្គាល់ ក្នុងការបង្កើតឱ្យមានទីប្រជែងជាស្ថាប័នស្មើគ្នារវាងស្ត្រី និងបុរស ។ ស្ថានភាពនេះ បើកផ្លូវឱ្យមានបរិយាកាសដែលឱ្យផលចំពោះ ការការពារសិទ្ធិស្មើគ្នារបស់ស្ត្រី ។ ជាអកុសល ការពិតគឺខុសប្លែកពីនេះយ៉ាងខ្លាំង ។ ការរិតបន្តឹងពីសង្គមវប្បធម៌ និងអសមត្ថភាព ក្នុងការអនុវត្តច្បាប់នេះមានន័យថា ការពិតច្បាប់ទាំងនោះមានការអនុវត្តតិចតួចណាស់ ហើយយុទ្ធសាស្ត្រក៏មិនទាន់បានអនុវត្តពេញលេញទៀត ។ ការប្រឹងប្រែងពង្រឹងសមត្ថភាពអនុវត្តច្បាប់នៃភ្នាក់ងារតុលាការ និងរដ្ឋបាលមានសារៈសំខាន់ចាំបាច់ដាច់ខាត បើសិនជាយើងចង់សំរេចបានសមភាពយេនឌ័រ ក្នុងសិទ្ធិជាមូលដ្ឋាន ។

អនុសញ្ញាស៊ី-ដ
ការពារស្ត្រីទូទាំង ប្រទេស
នូវរាល់ស្ថានភាពនៃជីវិត
ក្នុងគ្រួសារ និងសង្គមព្រម
ទាំងនូវ រាល់ស្ថានភាពការងារ ។



# យន្តការសំរាប់ រៀបចំទារៈ

# សមភាពយេនឌ័រប្រចាំ សហស្សវត្សរ៍

# ៤

*ខណៈដែលការលូតលាស់អាចកើតមានដោយគ្មានការកាត់បន្ថយភាពក្រីក្រ តែការកាត់បន្ថយភាពក្រីក្រ មិនអាចកើតមានដោយគ្មានការលូតលាស់នោះទេ ។ ការលូតលាស់គឺជាអាវុធដ៏ពូកែបំផុតក្នុងការប្រយុទ្ធ នឹងភាពក្រីក្រ ។*

**យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ**

## គោលដៅអភិវឌ្ឍន៍ប្រចាំសហស្សវត្សរ៍

**គោលដៅអភិវឌ្ឍន៍ប្រចាំសហស្សវត្សរ៍** ប្រសូត្រចេញមកពីសេចក្តីប្រកាសសហស្សវត្សរ៍ ដែលជាការយល់ព្រមរួមជាសាកល តាមបែបកុងសង់ស៊ុស ព្រមព្រៀងគ្នាក្នុងឆ្នាំ២០០០ ដោយប្រទេសជាសមាជិកចំនួន១៨៩ នៃអង្គការសហប្រជាជាតិ ។ សេចក្តីប្រកាសនេះ បានលើកឡើងនូវទស្សនប្បញ្ញត្តិ នៃពិភពលោកមួយ អំពីលក្ខខណ្ឌដែលត្រូវបានកែលម្អ សម្រាប់មនុស្សគ្រប់រូប រួមមានការលុបបំបាត់ភាពក្រីក្រ សន្តិភាព និងសន្តិសុខ កិច្ចការពារបរិស្ថាន សិទ្ធិមនុស្ស និងប្រជាធិបតេយ្យ ។ បញ្ហាអន្តរវិស័យមួយនៅគ្រប់គោលដៅទាំងនោះ គឺសិទ្ធិរបស់ស្ត្រីដូចដែលគេបានទទួលស្គាល់ជាសាកលថា ការធ្វើឱ្យឋានៈរបស់ស្ត្រី និងជីវិតរបស់ពួកគេប្រសើរឡើង គឺជាកូនសោសម្រាប់បើកទ្វារឱ្យការអភិវឌ្ឍ កំរិតជីវភាពរស់នៅកាន់តែខ្ពស់ មានសមភាព និងយុត្តិធម៌ព្រមទាំងដើម្បីធ្វើឱ្យអភិវឌ្ឍន៍មាន ចេរភាពពិតប្រាកដដល់ស្ត្រីដែលមានចំនួនដល់ទៅពាក់កណ្តាលនៃប្រជាជនពិភពលោកនោះ ។ តែដែលជាអកុសល ចំនួនប្រហែល ៧០%

នៃចំនួនពួកគេ ជាអ្នកក្រក្នុងសាកលលោក ពួកគេត្រូវតែបានរាប់បញ្ចូលទៅក្នុងដំណើរការធ្វើឱ្យសម្រេចគោលបំណងអភិវឌ្ឍន៍ សហស្សវត្សរ៍នេះ ។

## គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍មាន :

១- លុបបំបាត់ភាពក្រីក្រនិងភាពអត់ឃ្លាន

២- សម្រេចនូវការអប់រំបឋមសិក្សាជាសាកល

៣- លើកស្ទួយសមភាពយេនឌ័រ និងផ្តល់អំណាចដល់ស្ត្រី

៤- កាត់បន្ថយមរណៈរបស់កុមារ

៥- ពង្រឹងសុខភាពរបស់មាតា

៦- ប្រយុទ្ធប្រឆាំងនឹងជំងឺអេដស៍ ជំងឺគ្រុនចាញ់ និងជំងឺដទៃទៀត

៧- ធានាចេរភាពបរិស្ថាន

៨- ពង្រីកភាពជាដៃគូជាសាកល សម្រាប់កិច្ចអភិវឌ្ឍ

(ដកស្រង់ចេញពីសៀវភៅ **មាគ៌ាឆ្ពោះទៅរកសមភាពយេនឌ័រ** បកប្រែ និងរៀបរៀងដោយអង្គការសីលការ ខែធ្នូ ឆ្នាំ ២០០៥ - ទំ.៨)

## គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា

ក្នុងឆ្នាំ២០០៣ ប្រទេសកម្ពុជាយកលំនាំ តាមគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ ដើម្បីឆ្លើយតប នឹងសេចក្តីត្រូវការនៃការអភិវឌ្ឍជាក់ដោយឡែករបស់ប្រជាជនកម្ពុជា ។ ដោយទទួលស្គាល់ថា រនាំងស្ទះមួយក្នុងបណ្តារនាំងស្ទះចម្បង៧ដល់ការអភិវឌ្ឍគឺ ការខូចខាត ដីធ្លីដែលបណ្តាលមកពីគ្រាប់មីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ (UXO) នៅលើប្រមាណ ១២% នៃចំនួន

ដីភូមិរបស់ខ្មែរ ដូច្នេះកម្ពុជាបានបន្ថែមការកំចាត់មីន ជាគោលដៅអភិវឌ្ឍន៍ទី៩ បន្ថែមទៅលើគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ចម្បងទាំង៨ ដែលអនុវត្តនៅតាមប្រទេសនិមួយៗ ។ ដូចគ្នានឹងសូចនាករក្នុងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ (MDGs) សូចនាករនិមួយៗក្នុងគោលដៅអភិវឌ្ឍន៍សហស្សវត្សកម្ពុជា (CMDGs) មានទីដៅឆ្លងឆ្លើយ ដែលឆ្លុះបញ្ចាំង នូវកម្រិតពិតប្រាកដ ដែលអាចសម្រេចបានក្នុងឆ្នាំ ២០១៥ ។ ទីដៅនីមួយៗត្រូវបានវាស់វែង ដើម្បីបង្ហាញថាតើកម្ពុជាសម្រេចបានយ៉ាងដូចម្តេច ក្នុងបណ្តាគោលដៅ ចម្បងៗ នៃគោលដៅទាំងអស់ ។



## ផែនការសកម្មភាពទីក្រុងប៉េកាំង [វេទិកាប៉េកាំងសំរាប់ប្រតិបត្តិ]

នៅខែកញ្ញាឆ្នាំ១៩៩៥ បុរសនិងស្ត្រីរាប់ពាន់នាក់មកពីជុំវិញពិភពលោក ជួបជុំគ្នាក្នុងមហាសន្និបាត ពិភពលោកលើកទី៤ស្តីពីស្ត្រី នៅទីក្រុងប៉េកាំង ។ **វេទិកាសម្រាប់កិច្ចការ** គឺជារបៀបវារៈការងារ សម្រាប់ការបង្អាចដល់ស្ត្រី ។ គេប៉ងកំចាត់ឧបសគ្គដល់ការចូលរួមដ៏សកម្មរបស់ស្ត្រីនៅគ្រប់វិស័យសាធារណៈ និងឯកជននៃជីវិត តាមរយៈការចែករំលែកពេញលេញ និងស្មើភាពគ្នានៅក្នុងការសម្រេចចិត្តក្នុងវិស័យសេដ្ឋកិច្ច សង្គម វប្បធម៌ និងនយោបាយ ។ គោលការណ៍ បុរសចែករំលែកអំណាច និងការទទួលខុសត្រូវទាំងឡាយ

គប្បីធ្វើឡើងជាមួយស្ត្រីនៅតាមផ្ទះ កន្លែងធ្វើការងារ សហគមន៍ជាតិ និងអន្តរជាតិ ឱ្យបានកាន់តែទូលំទូលាយ ។ សមភាពរវាងស្ត្រី និងបុរស គឺជារឿងសិទ្ធិមនុស្ស និងជាលក្ខខណ្ឌមួយសម្រាប់យុត្តិធម៌សង្គម ហើយក៏ជាកត្តាមូលដ្ឋាន ចាំបាច់ដែលត្រូវបំពេញជាបឋម សម្រាប់សមភាព វឌ្ឍនភាព និងសន្តិភាព ។ ភាពជាដៃគូដែលបានបំលែង ផ្អែកលើ មូលដ្ឋានសមភាពរវាងស្ត្រី និង បុរស គឺជាលក្ខខណ្ឌមួយសម្រាប់ អភិវឌ្ឍន៍ប្រកបដោយ ចីរភាព ដែលមានមជ្ឈដ្ឋានក្នុងប្រជាពលរដ្ឋ ។ ក្នុងការប្តេជ្ញាចិត្តប្រកប ដោយចីរភាព និងរយៈពេលវែងមានសារៈសំខាន់ដើម្បីធ្វើឱ្យស្ត្រី និងបុរសអាចធ្វើការងារជាមួយគ្នា ដើម្បីពួកគេទាំងអស់គ្នា កូនចៅរបស់គេ និងសម្រាប់សង្គមគេ ដើម្បីដោះស្រាយបញ្ហា ប្រឈមប្រជែង នៅសតវត្សទី២១ ។

## វិស័យសំខាន់បំផុត ចំនួន១២ នៃវេទិកាប៉េកាំងសម្រាប់កិច្ច មាន ៖

- ស្ត្រី និងភាពក្រីក្រ
- ការអប់រំនិងបណ្តុះបណ្តាលរបស់ស្ត្រី
- សុខភាពស្ត្រី
- ហិង្សាលើស្ត្រី
- ស្ត្រីនិងជម្លោះប្រដាប់អាវុធ
- ស្ត្រីនិងសេដ្ឋកិច្ច
- ស្ត្រីនៅក្នុងអំណាច និងការធ្វើសេចក្តីសម្រេចចិត្ត
- យន្តការស្ថាប័នដើម្បីធ្វើឱ្យចម្រើនទៅមុខសម្រាប់ស្ត្រី
- សិទ្ធិមនុស្សរបស់ស្ត្រី
- ស្ត្រី និងប្រព័ន្ធផ្សព្វផ្សាយ
- ស្ត្រី និងបរិស្ថាន
- កុមារី

## ទំនាក់ទំនងរវាងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍សាកល គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា និងវេទិកាប៉េកាំងសម្រាប់កិច្ចការ

## ឆ្លុះបញ្ចាំងទៅនឹងអនុសញ្ញាស៊ីដ




ដើម្បីឱ្យបានសម្រេចនូវគោលដៅថ្នាក់ជាតិ មានមួយជំហានថែមទៀតដែលគេត្រូវតែធ្វើ ហើយបំភ្លឺពីគោលដៅជាក់លាក់ពីសូចនាករ ព្រមទាំងយុទ្ធសាស្រ្តនានាផង ។ ជាមួយនឹងការណែនាំនៃក្របខណ្ឌការងារ ដែលមានស្រាប់ ដូចជាអនុសញ្ញា**ស៊ី-ដ** ព្រមទាំង**ផែនការសកម្មភាពទីក្រុងប៉េកាំង** យើងពិតជាសម្បូរទៅដោយបញ្ហាទាក់ទិននឹងសមភាពយេនឌ័រ ដែលយើងអាចប្រើប្រាស់បាន ដើម្បីផ្សាភ្ជាប់ទៅនឹងបៀបវារៈនៃ**គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍** សម្រាប់បំពេញតម្រូវការដោយឡែកនៅកម្ពុជា ។ **ក្របខណ្ឌការងារទាំងបី** នេះទាក់ទងនិងគាំទ្រគ្នាទៅវិញទៅមកពី "**សមធម៌យេនឌ័រ**" ដែលពួកងរំពងនៅគ្រប់គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍នោះ ។ នៅក្នុងផ្នែកនេះយើងនឹងពិនិត្យ មើលបញ្ហានៃសមភាពយេនឌ័រ ដែលគោលដៅនិមួយៗលើកឡើងរួមទាំងកាតព្វកិច្ច និងការប្តេជ្ញាចិត្តដែលទាក់ទិន និងបានអនុលោមទៅតាមអនុសញ្ញា ស៊ី-ដ និង**វេទិកាប៉េកាំងសម្រាប់កិច្ចការ** ។

គោលដៅទី ១

# កាត់បន្ថយនូវភាពក្រីក្រធ្ងន់ធ្ងរ និងភាពអត់ឃ្លាន

**គោលដៅរួម** : សំរាប់ ឆ្នាំ ២០១៥

- កាត់បន្ថយពាក់កណ្តាល នូវសមាមាត្រប្រជាជន ដែលមានចំណូលតិចជាង ១ ដុល្លា ក្នុងមួយថ្ងៃ
- កាត់បន្ថយពាក់កណ្តាល នូវសមាមាត្រប្រជាជន ដែលមានការអត់ឃ្លាន

## អនុសញ្ញាស៊ីដ

### មាត្រា ១១ : ការបំរើការងារ

- រដ្ឋាភិបាលធានាសមភាពជូនចំពោះស្ត្រីនៅគ្រប់មុខនៃការបំរើការងារ ជាពិសេស ពាក់ព័ន្ធ នឹងឱកាសស្មើគ្នា ការជ្រើសរើសវិជ្ជាជីវៈដោយសេរី បំណាច់នានា លក្ខខណ្ឌនៃសេវាការងារ ការទទួលបានការបណ្តុះបណ្តាលវិជ្ជាជីវៈ និង ការទទួលបានថ្លៃឈ្នួលស្មើគ្នា សំរាប់ការងារ មានតំលៃស្មើគ្នា ។

### មាត្រា ១៣ : វិស័យសេដ្ឋកិច្ច កីឡា និងវប្បធម៌នៃជីវិត

- រដ្ឋាភិបាលត្រូវធានាថាស្ត្រីត្រូវទទួលបាននូវភាពស្មើគ្នា ក្នុងវិស័យសេដ្ឋកិច្ច និងសង្គម
- ស្ត្រីត្រូវទទួលបានភាពស្មើគ្នាក្នុងការទទួល

## ផែនការសកម្មភាពនីរុត្តិខេម៉ាំង

### គោលបំណងយុទ្ធសាស្ត្រ A.2 :

- ពិនិត្យឡើងវិញនូវច្បាប់ និងការអនុវត្ត រដ្ឋបាល ដើម្បីធានាសិទ្ធិស្មើគ្នារបស់ស្ត្រី និងឱកាសទទួលបាននូវធនធានសេដ្ឋកិច្ច ។

### គោលបំណងយុទ្ធសាស្ត្រ A.3 :

- ផ្តល់ឱ្យស្ត្រីទទួលនូវការសន្សំប្រាក់ យន្តការឥណទាន និងការបង្កើតស្ថាប័ន ក្នុងវិស័យនេះ ។

### គោលបំណងយុទ្ធសាស្ត្រ A. 4 :

- អភិវឌ្ឍវិធីសាស្ត្រផ្អែកលើ យេនឌ័រ និងធ្វើការស្រាវជ្រាវ ដើម្បីដោះស្រាយភាពក្រីក្ររបស់ស្ត្រី ។

### គោលបំណងយុទ្ធសាស្ត្រ F.1 :

- លើកស្ទួយនូវសិទ្ធិសេដ្ឋកិច្ច និងឯករាជភាពរបស់ស្ត្រីរួមទាំងឱកាសទទួលការងារ លក្ខខណ្ឌការងារសមរម្យ និងការគ្រប់គ្រង

បំណាច់សម្រាប់គ្រួសារការខ្ចីប្រាក់ និងរាល់សណ្ឋាននៃឥណទាន

### មាត្រា ១៤ : ស្ត្រីជនបទ

- រដ្ឋាភិបាលត្រូវធានាឱ្យតម្រូវការដោយឡែករបស់ស្ត្រីនៅជនបទត្រូវបានដោះស្រាយរួមមានការទទួលបានសេវា ឱកាសបណ្តុះបណ្តាល និងការបំរើការងារព្រមទាំងកម្មវិធីសមធមិសង្គម ហើយអនុម័តច្បាប់ ដើម្បីលុបបំបាត់ការរើសអើងប្រឆាំងនឹងពួកគេ ។

### មាត្រា ១៥ : សមភាពចំពោះមុខច្បាប់

- រដ្ឋាភិបាលត្រូវផ្តល់ចំពោះស្ត្រី នូវសមភាពជាមួយនឹងបុរសចំពោះមុខច្បាប់ រួមមានសិទ្ធិ ចូលរួមក្នុងការចុះកិច្ចសន្យាក្នុងការអភិបាល ទ្រព្យសម្បត្តិ ក្នុងការកាត់ក្តីក្នុងតុលាការ ឬសាលាក្តី និងក្នុងការជ្រើសរើសលំនៅស្ថាន និងទីកន្លែងរស់នៅ ។

### មាត្រា ១៦ : អាពាហ៍ពិពាហ៍ និង ច្បាប់

- រដ្ឋាភិបាលត្រូវធានាថាស្ត្រី និងបុរសមានសិទ្ធិស្មើគ្នាក្នុងអាពាហ៍ពិពាហ៍ និងក្នុងជីវិតគ្រួសារ ។
- ជាពិសេសមាន សិទ្ធិដូចគ្នារវាងប្តីប្រពន្ធក្នុងការទទួលខុសត្រូវ កម្មសិទ្ធិទ្រព្យសម្បត្តិធនធានសេដ្ឋកិច្ច ។

### គោលបំណងយុទ្ធសាស្ត្រ F.2 :

- សម្រួលដល់ឱកាសស្មើគ្នារបស់ស្ត្រី ក្នុងការទទួលនូវ ធនធាន ការងារទីផ្សារ និងពាណិជ្ជកម្ម ។

### គោលបំណងយុទ្ធសាស្ត្រ F.3 :

- ផ្តល់សេវាកម្មជំនួញ ការបណ្តុះបណ្តាល និងឱកាស ទីផ្សារ ព័ត៌មាន និងបច្ចេកវិទ្យា ជាពិសេស ចំពោះ ស្ត្រីដែលមានប្រាក់ចំណូលទាប ។

### គោលបំណងយុទ្ធសាស្ត្រ F.4 :

- ពង្រឹងសមត្ថភាពសេដ្ឋកិច្ច និងបណ្តាញពាណិជ្ជកម្ម របស់ស្ត្រី ។

### គោលបំណងយុទ្ធសាស្ត្រ F.5 :

- លុបបំបាត់រាល់ការបែងចែកវណ្ណៈក្នុងការងារ និង ការរើសអើងការងារគ្រប់រូបភាព ។

### គោលបំណងយុទ្ធសាស្ត្រ F.6 :

- លើកស្ទួយភាពសុខដុមរមនានៃការងារ និងការទទួល ខុសត្រូវចំពោះគ្រួសារស្ត្រី និងបុរស ។

**សូចនាកររបស់**

**យុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ យ.អ.ជ**

ក្នុង អាពាហ៍ពិពាហ៍និងការលែងលះព្រម ទាំងមានសិទ្ធិស្មើគ្នា នៅមុខរឿងទាក់ទង នឹងកំណើតកូន ការសុំកូនមកចិញ្ចឹម

- ព្រមទាំងការចិញ្ចឹមបីបាច់កូន ។

| ចំនុចដៅសូចនាករ | 2004 | 2010 |
|---|---|---|
| ក៏រឹតក្រីក្រ % នៃ ប្រជាពលរដ្ឋសរុប | 34.7% | 25% |

គោលដៅទី

## ២ សម្រេចការអប់រំ ចប់ថ្នាក់បឋមសិក្សាទូទៅ

**គោលដៅរួម** : សំរាប់ ឆ្នាំ ២០១៥

- ធានាឱ្យកុមារទាំងអស់ បានបញ្ចប់ការបឋមសិក្សាក្នុងឆ្នាំ ២០១០ និងបានបញ្ចប់ ការសិក្សា៩ឆ្នាំ ជាមូលដ្ឋាននៅឆ្នាំ ២០១៥ ។

### អនុសញ្ញាស៊ីដ

**មាត្រា ១០ : សិទ្ធិស្មើគ្នាក្នុងការអប់រំ**

- រដ្ឋាភិបាលត្រូវអនុម័តច្បាប់ ដើម្បីលុបបំបាត់ ការរើសអើងប្រឆាំងនិងនារីភេទក្នុងការអប់រំ ។ ករណីនេះ រួមទាំងផ្តល់ឱ្យស្ត្រី និងបុរសឱ្យ ទទួលបាន :
    - ការអប់រំ និងការណែនាំអំពីវិជ្ជាជីវៈ
    - មុខវិជ្ជារៀននិងបទដ្ឋានដូចគ្នា
    - ការអប់រំមនុស្សធំ និង

### ផែនការសកម្មភាពទីក្រុងប៉េកាំង

**គោលបំណងយុទ្ធសាស្ត្រ B.1 :**

- ធានាឱកាសទទួលបានការអប់រំស្មើគ្នា

**គោលបំណងយុទ្ធសាស្ត្រ L.4 :**

- លុបបំបាត់ការរើសអើង លើក្មេងស្រីក្នុង ការអប់រំពង្រីកជំនាញ និងការ បណ្តុះបណ្តាល ។

**គោលបំណងយុទ្ធសាស្ត្រ B.4 :**

- អភិវឌ្ឍការអប់រំ និងការបណ្តុះបណ្តាល

- ព័ត៌មានពីផែនការគ្រួសារ

**មាត្រា ១៤ : ស្ត្រីជនបទ**

- រដ្ឋាភិបាលត្រូវធានាឱ្យតម្រូវការដោយឡែករបស់ស្ត្រីនៅជនបទ ត្រូវបានដោះស្រាយ ទាក់ទង នឹងការទទួលបាន សេវានានា ការបណ្តុះបណ្តាល និងការអប់រំ ។

**អនុសាសន៍ទូទៅ ទី ១៩**

- ប្រកាន់យកភាពត្រឹមត្រូវតាមផ្លូវច្បាប់ និង វិធានការដទៃ ទៀត ដើម្បីផ្តល់ការការពារប្រកបដោយប្រសិទ្ធភាព ប្រឆាំងចំពោះ អំពើហិង្សាទាក់ទង នឹងយេនឌ័រ ។

ដែលគ្មានការរើសអើង

**គោលបំណងយុទ្ធសាស្ត្រ B.5 :**

- ស្វែងរកការគាំទ្រផ្នែកធនធានឱ្យបានគ្រប់គ្រាន់ សម្រាប់ត្រួតពិនិត្យការអនុវត្ត និងការកែទម្រង់វិស័យអប់រំ ។

**គោលបំណងយុទ្ធសាស្ត្រ L.7. :**

- លុបបំបាត់អំពើហិង្សាលើកុមារី ។

## សូចនាកររបស់
## យុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ យអជ

| ចំនុចដៅ/សូចនាករ | 2005 | 2010 |
|---|---|---|
| ចំនួនសិស្សនារីចុះឈ្មោះចូលរៀនបឋមសិក្សា | 90.7% | 100% |
| ចំនួនសិស្សនារីចុះឈ្មោះចូលរៀនមធ្យមសិក្សា | 24.8 | 75% |

គោលដៅទី ៣

# លើកកំពស់សមភាពយេនឌ័រ និងផ្តល់អំណាចស្ត្រី

**គោលដៅរួម** : សំរាប់ ឆ្នាំ ២០១៥

- លុបបំបាត់នូវភាពខុសគ្នាផ្នែកយេនឌ័រ ក្នុងការអប់រំ ៩ ឆ្នាំ ជាមូលដ្ឋាន
- កាត់បន្ថយឱ្យបានច្រើនគំលាតយេនឌ័រ ក្នុងការអប់រំនៅ មធ្យមសិក្សាទុតិយភូមិ និងការអប់រំនៅឧត្តមសិក្សា
- លុបបំបាត់ ភាពខុសគ្នាផ្នែកយេនឌ័រ ពីការទទួលថ្លៃឈ្នួលក្នុងការបំរើការងារ នៅគ្រប់វិស័យក្នុងសេដ្ឋកិច្ច
- លុបបំបាត់នូវគំលាតផ្នែកយេនឌ័រ ក្នុងជួររដ្ឋាភិបាល ។
- បង្កើនសមមាត្រស្រីក្នុងរដ្ឋសភាឱ្យបាន៣០% និងក្រុមប្រឹក្សាឃុំឱ្យបាន២៥% ។

## អនុសញ្ញាស៊ីដ

### មាត្រា ២ : វិធានការនៃគោលនយោបាយ ដែលត្រូវអនុម័តយក

- បញ្ចូលនូវគោលការណ៍នៃសមភាពរវាងស្ត្រី និងបុរស ក្នុងអង្គនៃរដ្ឋធម្មនុញ្ញជាតិ
    - ទាំងនេះរួមមានការលុបចោលនូវរាល់ច្បាប់ ទំនៀមទម្លាប់ និងបទបញ្ជាទាំងឡាយណា ដែលមានភាពរើសអើង
    - អនុម័តវិធានការច្បាប់ ដើម្បីហាមប្រាមរាល់ សណ្ឋាននៃការ

## ផែនការសកម្មភាពនីត្រូវប៉េកាំង

### គោលបំណងយុទ្ធសាស្ត្រ I.1 :

- ធានាឱ្យមានសមភាព និងការមិនរើសអើង ចំពោះច្បាប់ និងក្នុងការអនុវត្តផ្ទាល់ ។

### គោលបំណងយុទ្ធសាស្ត្រ H.2 :

- បញ្ចូលទស្សនៈយេនឌ័រទៅក្នុងច្បាប់ គោលនយោបាយសាធារណៈ កម្មវិធី និងគម្រោង ។

រើសអើងប្រឆាំងនឹងនារីភេទ ដើម្បីធានា ឱ្យមានការទទួលបាននូវកិច្ចការពារ ឱ្យចាកផុតពីការរើសអើង តាមរយៈសាលាក្តីនានា ឬតាមរយៈស្ថាប័នសាធារណៈដទៃទៀត ។

**អនុសាសន៍ទូទៅ ទី ៦ :**

- បង្កើតឡើង និង/ឬ ពង្រឹងប្រសិទ្ធភាពយន្តការជាតិ ដែលបានគាំទ្រដោយការបញ្ជ្រាបយេនឌ័រនៅក្នុងគ្រប់ ក្រសួងនៃរដ្ឋាភិបាល ហើយជួយតាក់តែងនូវគោល នយោបាយថ្មីៗ ហើយអនុវត្តឱ្យមានប្រសិទ្ធភាពនូវយុទ្ធសាស្ត្រ និងវិធានការ ដើម្បីលុបបំបាត់ការរើសអើង ។

**គោលបំណងយុទ្ធសាស្ត្រ H.3 :**

- បង្កើត និងផ្សព្វផ្សាយទិន្នន័យនិងព័ត៌មាន ទាក់ទងនឹងយេនឌ័រដែលបានបែកខ្ញែកពី គ្នាសម្រាប់ការរៀបចំផែនការ និងការ វាយតម្លៃ។

**គោលបំណងយុទ្ធសាស្ត្រ H.1 :**

- បង្កើត និងពង្រឹងក្បាលម៉ាស៊ីនដឹកនាំថ្នាក់ជាតិ និងស្ថាប័នរដ្ឋាភិបាលផ្សេងៗទៀត ។

## សូចនាកររបស់ យុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ យ.អ.៩

| ចំនុចដៅ/សូចនាករ | 2005 | 2010 |
|---|---|---|
| បញ្ជ្រាបយេនឌ័រ នៅគ្រប់វិស័យ | **នឹងរៀបចំ** | |
| អត្រាស្ត្រីដែលធ្វើការបានប្រាក់កំរៃ ក្នុងវិស័យកសិកម្ម | 52.5%; | 50%; |
| ឧស្សាហកម្ម | 53.5%; | 50%; |
| សេវាកម្ម | 27% | 37% |
| ក៏រីតដែលយល់ដឹងអំពីហឹង្សាក្នុងគ្រួសារប្រឆាំងនិងស្ត្រី ថាជាបទឧក្រិដ្ឋ | 4.5% | 25% |

គោលដៅទី

**៤ & ៥**

# កាត់បន្ថយអត្រាមរណៈរបស់កុមារ និងបង្កើនសុខភាពមាតា

**គោលដៅរួម** : សំរាប់ ឆ្នាំ ២០១៥

- កាត់បន្ថយឱ្យបានច្រើន នូវរាល់សណ្ឋាននៃអំពើហិង្សា ប្រឆាំងស្ត្រី និងកុមារ
- កាត់បន្ថយអត្រាស្លាប់របស់កុមារ ក្រោមអាយុប្រាំឆ្នាំ
- កាត់បន្ថយអត្រាស្លាប់របស់មាតា

## អនុសញ្ញាស៊ីដ

### មាត្រា ១០ : សិទ្ធិទទួលការអប់រំ

- រដ្ឋាភិបាលត្រូវលុបបំបាត់ការរើសអើងក្នុងការអប់រំ ដើម្បីធានាឱ្យស្ត្រីបានទទួលព័ត៌មានពីការអប់រំ ដែលធានា ដល់សុខភាព និងសុខុមាលភាពនៃគ្រួសាររួមមាន ព័ត៌មាន និងយោបល់ប្រឹក្សាអំពីផែនការគ្រួសារ ។

### មាត្រា ១២ : ការថែទាំសុខភាព

- រដ្ឋាភិបាលត្រូវអនុម័តច្បាប់លុបបំបាត់ការរើសអើង ប្រឆាំងចំពោះស្ត្រីក្នុងវិស័យសុខភាព ហើយផ្ដល់ឱ្យទទួល បាននូវសេវាថែទាំសុខភាពលើមូលដ្ឋាននៃការទទួលបានស្មើគ្នា រួមទាំងសេវាទាក់ទងនឹងធ្វើផែនការ

## ផែនការសកម្មភាពទីក្រុងប៉េកាំង

### គោលបំណងយុទ្ធសាស្ត្រ C.1 :

- បង្កើនឱកាសដល់ស្ត្រីពេញមួយជីវិត ដើម្បីទទួលបានការគាំពារសុខភាព ឱ្យបានសមរម្យ គ្រប់គ្រាន់ និងប្រកបដោយគុណភាព ព្រមទាំងទទួលបានព័ត៌មាន និងសេវាកម្មផ្សេងៗ ។

### គោលបំណងយុទ្ធសាស្ត្រ C.2 :

- ពង្រឹងកម្មវិធីចាក់ថ្នាំបង្ការទាំងឡាយដែលលើកស្ទួយសុខភាពស្ត្រី ។

### គោលបំណងយុទ្ធសាស្ត្រ C.3 :

- អនុវត្តគំនិតផ្តួចផ្តើមឆ្លើយតបនឹងយេនឌ័រ ដែលដោះស្រាយជំងឺឆ្លងតាមផ្លូវភេទ ជំងឺអេដស៍ និងបញ្ហាសុខភាពបន្តពូជ និងសុខភាពផ្លូវភេទ ។

គ្រួសារ ផងដែរ ។

**មាត្រា ១៤ : ស្ត្រីជនបទ**

- រដ្ឋាភិបាលត្រូវធានាសិទ្ធិស្ត្រីមានទីសម្រួលសេវាសុខភាព គ្រប់គ្រាន់ រួមមានព័ត៌មានការផ្តល់ការពិគ្រោះយោបល់ និងសេវាផែនការគ្រួសារ ។

**អនុសាសន៍ទូទៅ ទី ១៩ :**

- រដ្ឋាភិបាលត្រូវលុបបំបាត់រាល់សណ្ឋាននៃអំពើហិង្សាទាក់ទងនឹងយេនឌ័រ ប្រឆាំងស្ត្រី ។

**គោលបំណងយុទ្ធសាស្ត្រ C.4 :**

- លើកស្ទួយការស្រាវជ្រាវ និងផ្សព្វផ្សាយព័ត៌មាន អំពីសុខភាពស្ត្រី ។

**គោលបំណងយុទ្ធសាស្ត្រ C.5 :**

- ពង្រីកធនធាន និងត្រួតពិនិត្យការតាម ដានចំពោះសុខភាពរបស់ស្ត្រី ។

**គោលបំណងយុទ្ធសាស្ត្រ L.5 :**

- លុបបំបាត់ការរើសអើងចំពោះនារីលើសុខភាព និងអាហារបំប៉ន ។

## សូចនាកររបស់ យុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ យ.អ.ជ

| ចំនុចដៅ/សូចនាករ | 2005 | 2010 |
|---|---|---|
| អត្រាស្លាប់នៃកុមារ ក្នុងចំនួន 1000 នាក់ | 66% | 60% |
| អត្រាស្លាប់នៃកុមារ ក្រោម៥ឆ្នាំ ក្នុងចំនួន 1000 នាក់ | 82% | 75% |
| កាត់បន្ថយអត្រាស្លាប់នៃមាតា[1] | | 243 |
| បង្កើតកូនដោយឆ្មបដែលមានបច្ចេកទេស[2] | | 70 |
| ស្ត្រីប្រើវិធីសាស្ត្រផែនការមានកូនតាមបច្ចេកទេសទំនើប[3] ( Methods ) | 20.1% | 44% |
| ភាគរយនៃមន្ទីរពេទ្យដែលផ្តល់សេវាសុខភាពផ្លូវភេទ | 33% | 45% |

[1] Maternal mortality rate per 100,000 live birth
[2] Birth attended by skilled health personnel
[3] Married women using modern birth spacing methods

គោលដៅទី

# ប្រយុទ្ធនឹងជំងឺអេដស៍ គ្រុនចាញ់ និងជំងឺផ្សេងៗ

# ៦

**គោលដៅរង** : សំរាប់ ឆ្នាំ ២០១៥

កាត់បន្ថយអត្រានៃការរីករាលដាលនៃ HIV និងជំងឺអេដស៍ គ្រុនចាញ់ ជំងឺគ្រុនឈាម និងជំងឺរបេង ។

## អនុសញ្ញាសុី-ដ

**មាត្រា ៥ : តួនាទីភេទ និង ផ្នត់គំនិត**

- រដ្ឋាភិបាលត្រូវមានវិធានការកែប្រែរបៀបរបប សង្គម និង វប្បធម៌ នៃឥរិយាមារយាទរបស់ បុរស-ស្ត្រី ដើម្បីលុប បំបាត់ផ្នត់គំនិតនានា ដែលមានរួមការលុបបំបាត់ផ្នត់គំនិត សង្គម និងវប្បធម៌ និងការប្រតិបត្តិនានា ផ្អែកលើ វិសមភាពយេនឌ័រ ។

**មាត្រា ៧ : វិស័យនយោបាយ និងសាធារណៈ នៃជីវិត**

- រដ្ឋាភិបាលត្រូវធានាសិទ្ធិរបស់ស្ត្រីឱ្យចូលរួមក្នុង ការតាក់ តែង និងអនុវត្តគោលនយោបាយកាន់ ដំណែងការិយាល័យ សាធារណៈ ហើយសម្តែង បំរើមុខងារសាធារណៈ នៅគ្រប់ ជាន់ថ្នាក់ រដ្ឋាភិបាល ។

**មាត្រា ១១ : សិទ្ធិបំរើការងារ**

## ផែនការសកម្មភាពនីក្រុងប៉េកាំង

**គោលបំណងយុទ្ធសាស្ត្រ L.2 :**

- លុបបំបាត់ចោលនូវឥរិយាបថ និងការ ប្រតិបត្តិវប្បធម៌អវិជ្ជមាន ចំពោះនារី ។

**គោលបំណងយុទ្ធសាស្ត្រ D.1 :**

- ចាត់វិធានការដាក់បញ្ចូលគ្នាដើម្បីទប់ស្កាត់ និងលុបបំបាត់ចោលអំពើហិង្សាលើស្ត្រី ។

**គោលបំណងយុទ្ធសាស្ត្រ F.1 :**

- លើកស្ទួយសិទ្ធិសេដ្ឋកិច្ចរបស់ស្ត្រី និងភាព ម្ចាស់ការ រួមទាំងឱកាសទទួលបាន ការងារ លក្ខខណ្ឌការងារសមរម្យ និងការគ្រប់គ្រងលើធនធានសេដ្ឋកិច្ច ។

**គោលបំណងយុទ្ធសាស្ត្រ C.1 :**

- បង្កើនឱកាសក្នុងជីវិតរបស់ស្ត្រី ឱ្យទទួល បានការគាំពារសុខភាពសមរម្យ គ្រប់គ្រាន់ និងប្រកបដោយគុណភាព ព្រមទាំងទទួល បានព័ត៌មាន និងសេវាដែលពាក់ព័ន្ធ ផ្សេងៗ ។

- រដ្ឋាភិបាលត្រូវលុបបំបាត់ការរើសអើងប្រឆាំងស្ត្រី ដើម្បី ធានាសិទ្ធិស្មើគ្នា សម្រាប់បុរស-ស្ត្រី ក្នុងការបំរើការងារ ។

### មាត្រា ១២ : សិទ្ធិមានសុខភាព

- រដ្ឋាភិបាលត្រូវធានាសិទ្ធិរបស់ស្ត្រី ឱ្យទទួលបានស្មើគ្នា នូវសេវាថែទាំសុខភាព ។

### មាត្រា ១៥ : សមភាពក្នុងវិស័យច្បាប់

- រដ្ឋាភិបាលត្រូវធានាចំពោះបុរស-ស្ត្រី នូវសិទ្ធិស្មើគ្នាក្នុងផ្លូវ ច្បាប់ ទាក់ទងនឹងកិច្ចសន្យានានា និងកម្មសិទ្ធិ ។

### មាត្រា ១៦ : សមភាពក្នុងអាពាហ៍ពិពាហ៍

- រដ្ឋាភិបាលត្រូវធានា សមភាពរវាងបុរស និងស្ត្រីក្នុងការ រៀបអាពាហ៍ពិពាហ៍ និងជីវិតគ្រួសារ ។

### អនុសាសន៍ទូទៅ ទី ១៥ :

- ចៀសវាងការរើសអើងប្រឆាំងស្ត្រីក្នុងយុទ្ធសាស្ត្រជាតិបង្ការ និងត្រួតពិនិត្យជំងឺអេដស៍ ។

### អនុសាសន៍ទូទៅ ទី ១៩ :

- លុបបំបាត់រាល់សណ្ឋាននៃអំពើហិង្សាទាក់ទងនឹងយេនឌ័រ ប្រឆាំងស្ត្រី ។

### គោលបំណងយុទ្ធសាស្ត្រ C.3 :

- អនុវត្តនូវគំនិតផ្តួចផ្តើមឆ្លើយតបយេនឌ័រ ដើម្បីដោះស្រាយជំងឺឆ្លងតាមផ្លូវភេទ ជំងឺអេដស៍ និងបញ្ហាសុខភាពបន្តពូជ និងសុខភាពផ្លូវភេទ ។

### គោលបំណងយុទ្ធសាស្ត្រ G :

- ចាត់វិធានការ ដើម្បីធានាឱកាសស្មើគ្នា របស់ស្ត្រី និងការចូលរួមពេញលេញក្នុង រចនាសម្ព័ន្ធអំណាច និងការធ្វើសេចក្តីសម្រេចចិត្ត ។

## សូចនាកររបស់ យុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ យ.អ.ជ

| ចំនុចដៅ/សូចនាករ | 2005 | 2010 |
|---|---|---|
| HIV/AIDS ប្រេវ៉ាឡង់ក្នុងចំណោមមនុស្សធំ ពី១៥-៤៩ ឆ្នាំ | 1.9 | 1.9 |
| ស្លាប់ដោយជំងឺគ្រុនចាញ់ | 0.36 | 0.25 |
| អ្នកមានជំងឺ របេងក្នុងចំនួនមនុស្ស 100,000 | N/A | 214 |

គោលដៅទី

# ធានានិរន្តរភាពបរិស្ថាន

# ៧

**គោលដៅរង** : សំរាប់ ឆ្នាំ ២០១៥

- បញ្ចូលគោលការណ៍អភិវឌ្ឍន៍ប្រកបដោយចីរភាពទៅក្នុងគោលនយោបាយ និងកម្មវិធីជាតិ និងបង្កើនមកវិញនូវធនធានបរិស្ថានដែលបាត់បង់
- កាត់បន្ថយពាក់កណ្តាល នូវសមាមាត្រប្រជាជន ដែលមិនអាចទទួលបានប្រកបដោយចីរភាព នូវទឹកស្អាត
- កាត់បន្ថយពាក់កណ្តាល នូវសមាមាត្រប្រជាជន ដែលមិនអាចទទួលបានអនាម័យល្អប្រកបដោយចីរភាព
- បង្កើនអត្រាប្រជាជន ទាំងនៅទីប្រជុំជន ទាំងនៅជនបទ ឱ្យទទួលបានសន្តិសុខដីធ្លី ។

## អនុសញ្ញាស៊ីដ

**មាត្រា ១៤ : ស្ត្រីជនបទ**

- រដ្ឋាភិបាលត្រូវធានាឱ្យតម្រូវការដោយឡែករបស់ស្ត្រីនៅ ជនបទត្រូវបានដោះស្រាយ ទាក់ទងនឹងការទទួលបាន សេវាឱកាសបណ្តុះបណ្តាល និងការបំរើការងារ ព្រមទាំង កម្មវិធីសមធម៌សង្គម ហើយអនុម័តច្បាប់ ដើម្បីលុបបំបាត់ ការរើសអើងប្រឆាំងនឹងពួកគេ ។

## ផែនការសកម្មភាពនីត្រូវបេកាំង

**គោលបំណងយុទ្ធសាស្ត្រ K.1 :**

- ឱ្យស្ត្រីឱ្យបានចូលរួមយ៉ាងសកម្ម ក្នុងការសម្រេចចិត្ត ទាក់ទងនឹងបរិស្ថាន នៅគ្រប់កម្រិត ។

**គោលបំណងយុទ្ធសាស្ត្រ K. 2 :**

- ដាក់បញ្ចូលការងារ និងទស្សនៈយេនឌ័រទៅក្នុងគោលនយោបាយ និងកម្មវិធីសម្រាប់ការអភិវឌ្ឍយូរអង្វែង ។

**គោលបំណងយុទ្ធសាស្ត្រ K.3 :**

- ដោយឡែក មានបញ្ហាដែលស្ត្រីនៅជនបទបានប្រឈមមុខ និងមានតួនាទីសំខាន់ដែលពួកគេដើរតួក្នុងការធ្វើឱ្យសេដ្ឋកិច្ចគ្រួសារមានជីវិតនោះ ស្ថានការនេះ ត្រូវធានាសិទ្ធិឱ្យស្ត្រី នៅជនបទ បានចូលរួមក្នុងការរៀបចំ និងអនុវត្តផែនការ អភិវឌ្ឍន៍នៅគ្រប់កម្រិត ។

- ពង្រឹង និងបង្កើតយន្តការ នៅតាមកម្រិតជាតិ តំបន់ និងអន្តរជាតិ ដើម្បីបានប្រមាណមើលនូវផលប៉ះពាល់ពីការអភិវឌ្ឍ និងគោលនយោបាយបរិស្ថាន ទៅលើស្ត្រី ។

## សូចនាកររបស់ យុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ យ.អ.ជ

| ចំនុចដៅ/សូចនាករ | 2005 | 2010 |
|---|---|---|
| ដីដែលមានព្រៃឈើ (% នៃផ្ទៃដីសរុប ) | 60% | 58% |
| ប្រជាជនមានទឹកស្អាតប្រើប្រាស់ (% នៃប្រជាជននៅទីក្រុង ) | 75.8% | 85% |
| គ្រួសារដែលដុតអុស ធ្យូងចំអិនអាហារ (% នៃគ្រួសារសរុប) | 83.9% | 61% |

គោលដៅទី ៨

# បង្កើតដៃគូជាសកល ដើម្បីអភិវឌ្ឍន៍

**គោលដៅរួម : សំរាប់ ឆ្នាំ ២០១៥ និង ២០២៥**

- បង្កើតតទៅទៀតនូវប្រព័ន្ធពាណិជ្ជកម្ម និងហិរញ្ញវត្ថុបើកចំហ ផ្អែកលើច្បាប់ ដែលអាចប្រមើលទុកជាមុន និងមិនរើសអើង
- ជួយឱ្យប្រទេសកំពុងអភិវឌ្ឍន៍អាចលៃលកទទួលបានឱសថចាំបាច់ ដោយសហការជាមួយក្រុមហ៊ុនឱសថ
- ដោយសហការណ៍ជាមួយវិស័យឯកជន បង្កើតលទ្ធភាពទាញយកផលប្រយោជន៍ពីបច្ចេកទេសថ្មីៗជាពិសេស បច្ចេកទេសព័ត៌មាន និងទំនាក់ទំនង

## ស៊ី_ដ

**មាត្រា ៨ :**

- ធានាឱ្យស្ត្រីមានឱកាសធ្វើជាតំណាងរបស់រដ្ឋាភិបាលខ្លួន នៅកំរិតអន្តរជាតិ និងធានាឱ្យបានចូលរួមក្នុងការងារនៃអង្គការអន្តរជាតិ ។

**មាត្រា ៧ :**

- រដ្ឋាភិបាលត្រូវធានាសិទ្ធិរបស់ស្ត្រីឱ្យចូលរួមក្នុងការតាក់តែង និងអនុវត្តគោលនយោបាយកាន់ដំណែងការិយាល័យសាធារណៈ ហើយសម្តែងបំរើមុខងារសាធារណៈ នៅគ្រប់ ជាន់ថ្នាក់រដ្ឋាភិបាល ។
- ធានាសិទ្ធិរបស់ស្ត្រី ក្នុងការចូលរួមក្នុងអង្គការមិនមែន រដ្ឋាភិបាល សមាគមនានា

## វេទិកាសកម្មភាពប៉េកាំង

**គោលបំណងយុទ្ធសាស្ត្រ A.1 :**

- ពិនិត្យឡើងវិញ អនុម័ត និងថែរក្សាគោលនយោបាយសេដ្ឋកិច្ចខ្នាតធំ និងយុទ្ធសាស្ត្រ នៃការអភិវឌ្ឍ ដែលអាចដោះស្រាយនូវ តម្រូវការ និងការខិតខំប្រឹងប្រែងរបស់ស្ត្រីក្នុងភាពក្រីក្រ ។

**គោលបំណងយុទ្ធសាស្ត្រ G.1 :**

- ចាត់វិធានការ ដើម្បីធានានូវឱកាសស្មើគ្នារបស់ស្ត្រី និងការចូលរួមពេញលេញនៅក្នុង រចនាសម្ព័ន្ធអំណាច និងការសម្រេចចិត្ត ។

ដែលយកចិត្តទុកដាក់ ចំពោះ ជីវិតសាធារណៈ និងនយោបាយរបស់ប្រទេស ។

**មាត្រា ១៤-2a :**

- ធានាសិទ្ធិរបស់ស្ត្រីជនបទ ក្នុងការចូលរួមការងារ និង អនុវត្តផែនការអភិវឌ្ឍន៍នៅគ្រប់កំរិត ។

## សូចនាកររបស់ យុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ យ.អ.ជ

| ចំនុចដៅ/សូចនាករ | 2005 | 2010 |
|---|---|---|
| ចំនួនគ្រោះថ្នាក់ (ស្លាប់និងរបួស) | 797 | 200 |
| ផ្ទៃដីដែលមានជាតិផ្ទុះ គិតជា % | 50.3% | 77% |

# យុទ្ធសាស្ត្រចតុកោណ ៥

*" ស្ត្រីគឺជាឆ្អឹងខ្នង នៃសេដ្ឋកិច្ច និងសង្គមជាតិយើង "*

ប្រសាសន៍បញ្ជាក់របស់ **សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន**

**ទំនាក់ទំនងរវាងយុទ្ធសាស្ត្រអភិវឌ្ឍន៍ចតុកោណ និងអនុសញ្ញាស៊ី-ដ**

នៅពេលដែលខ្នាតជាសាកលនានាត្រូវបានកំណត់ជាកំហិតដែល ឆ្លុះបញ្ចាំងអំពីគោលដៅ របស់សហគមន៍នៃប្រជាជាតិនានា ក្នុងគ្រប់ប្រភេទនៃវិស័យអភិវឌ្ឍន៍ រដ្ឋជាសមាជិកនីមួយៗ មានរួមទាំងកម្ពុជាផងដែរនោះ ក៏កំណត់សូចនាករជាកំហិត សម្រាប់សហស្សវត្សរ៍ខាងមុខដែរ ។ បន្ថែមលើនេះកម្ពុជាបានដាក់បញ្ចូលនូវ **គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា** (CMDGs[4]) ទៅក្នុង**ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ** (NSDPs[5]) ២០០៦-២០១០ របស់ខ្លួនដែលឆ្លុះបញ្ចាំងអំពីការចងក្រងនូវ **ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គម** របស់ខ្លួន (SEDP[6]) និងដំណើរការនៃ **យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ** (NPRS[7]) ដែលមានពីពេលមុន ។

**យុទ្ធសាស្ត្រចតុកោណ** ត្រូវបានលើកឡើង ដើម្បីធានានូវអចិន្ត្រៃយ៍ ការផ្តោតការយកចិត្តទុកដាក់សំដៅរកលទ្ធផល ហើយពង្រឹងថែមទៀតនូវសមិទ្ធផលទាំងឡាយ ដែលឈោងចាប់បានកាលពីក្នុង អាណត្តិទី២ នៃអង្គនីតិបញ្ញត្តិនៃរដ្ឋសភាជាតិ តាមរយៈការអនុវត្ត **យុទ្ធសាស្ត្រត្រីកោណ**នោះ ។ យុទ្ធសាស្ត្រចតុកោណ ក្រសោបនូវធាតុជាគន្លឹះនានា នៃគោល

4 Cambodian Millinium Development Goals
5 National Strategic Development Plan
6 Social Economic Development Plan
7 National Poverty Reduction Strategy

ដៅអភិវឌ្ឍន៍សហស្សវត្សរ៍ **ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គម**របស់កម្ពុជា ២០០១-២០០៥ (SEDP2) **យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ** ២០០៣-២០០៥ (NPRS) និងគោលនយោបាយ យុទ្ធសាស្ត្រ ផែនការ និងការផ្ដួចផ្ដើមគំនិតកែទម្រង់សំខាន់ៗដទៃទៀត ។

**យុទ្ធសាស្ត្រចតុកោណ**មានវត្ថុបំណងលើកកម្ពស់ការរីកចម្រើននៃសេដ្ឋកិច្ច និងការបង្កើតឱ្យមានការងារធ្វើសម្រាប់អ្នកធ្វើការងារកម្ពុជាទាំងឡាយឱ្យពេញលេញ **ដោយលើកតម្កើងសមភាព និងយុត្តិធម៌ សង្គម ក៏ដូចជាពង្រឹងភាពស័ក្តិសិទ្ធិ ក្នុងផ្នែកសាធារណៈ** ។

អ្វីៗទាំងអស់នេះមានលក្ខណៈចាំបាច់ជាដាច់ខាត ដើម្បីលើកកម្ពស់ការអភិវឌ្ឍប្រកបដោយចីរភាព និងការកាត់បន្ថយភាពក្រីក្រ ។

# អនុសញ្ញាស៊ី_ដ និងអ្នក ៦

**អនុសញ្ញាស៊ី-ដ នៅក្នុងជីវិតរបស់អ្នក**

**តើអ្នកអាចធ្វើអ្វីបានខ្លះ** ដើម្បី **ធ្វើឱ្យសិទ្ធិស្ត្រីបាន ទៅជាការពិតនៅកម្ពុជា?**



ធ្វើឱ្យសិទ្ធិស្ត្រីទៅជាការពិត ចាប់ផ្តើមពីគេហព័ន្ធ (Household) ។ នៅពេលដែលយើងយកពេលមកគិតពីវា "ភាពពិត "របស់យើងចាប់ផ្តើមពីក្នុងផ្ទះរបស់យើង ។ នេះជាមូលដ្ឋាន និងជាគ្រឹះរបស់យើង ។ គេហព័ន្ធគឺជាគ្រឹះ របស់សង្គមផងដែរ ។ យើងត្រូវប្រព្រឹត្ត ចំពោះគ្នាទៅវិញទៅមក ដោយសេចក្តីថ្លៃថ្នូរដោយមានការគោរព ការទទួលស្គាល់សិទ្ធិជាមូលដ្ឋានទាំងឡាយរបស់សមាជិកម្នាក់ៗនៃគេហព័ន្ធ ។ យើងនឹងបានសម្រេចនូវសិទ្ធិមនុស្ស និង សិទ្ធិស្ត្រីនៅក្នុងផ្ទះរបស់យើង ។ **នេះជាជំហានទីមួយ ដើម្បីធ្វើឱ្យសិទ្ធិស្ត្រី ទៅជាការពិត ។**

**ដូច្នេះ តើយើងត្រូវចាប់ផ្តើមពីទីណា ហើយតើយើងអាចធ្វើអ្វីបានខ្លះ?**

ឯកត្តជននិងសហគមន៍ទាំងឡាយ ចាំបាច់ត្រូវជ្រាបដឹងពីព័ត៌មាន អំពីសិទ្ធិរបស់ខ្លួន ហើយចូលរួមធ្វើការសម្រេចចិត្តនានា ដែលមានឥទ្ធិពលមកដល់ខ្លួន ។ រដ្ឋាភិបាល និងបណ្តាអ្នករាប់រង

ភារកិច្ចទាំងឡាយ ជានិច្ចកាលត្រូវការជំនួយដើម្បីអភិវឌ្ឍសមត្ថភាព និងធនធានដើម្បីបំពេញការប្តេជ្ញាចិត្តរបស់ខ្លួនចំពោះសិទ្ធិមនុស្ស ។ ដោយមូលហេតុនេះ យើងជាឯកត្តជនទាំងអស់គ្នាគួរដឹងពីតម្រូវការដែលឱ្យយើងចាប់ផ្តើមធ្វើដំណើរក្នុងផ្លូវចិត្តរៀង១ខ្លួន ផ្លាស់ប្តូរអាកប្បកិរិយា និងកិច្ចនានាដែលមានការរើសអើងចំពោះស្ត្រី ហើយដាក់ស្ត្រី និងបុរសឱ្យទៅក្នុងទីលានប្រជែងមិនស្មើគ្នា ។ បើយើងអាចធ្វើការជាមួយគ្នាបាននោះ យើងអាចធ្វើឱ្យសិទ្ធិស្ត្រីក្លាយទៅជាការពិតបាននៅកម្ពុជា ហើយបោះជំហានមួយយ៉ាងធំ ក្នុងការធ្វើឱ្យសង្គមនិងការអភិវឌ្ឍរបស់សង្គមកាន់តែល្អប្រសើរឡើង ។

### ក្នុងនាមជាឯកត្តជន

- ធ្វើអ្វី១ដើម្បីលុបបំបាត់ការរំលោភលើសិទ្ធិស្ត្រីទាំងឡាយ ទោះជាដោយបុគ្គល ឯកជន ក្រុម ឬអង្គការណាក៏ដោយ
- ខ្នះខ្នែងកែប្រែរបៀបរបបសង្គមវប្បធម៌នៃចរិយាមារយាទ ដែលបង្កើតជាផ្នត់គំនិតអំពីយេនឌ័រ ឬដាក់ស្ត្រីក្នុងតំណែងទាប
- ធានាឱ្យស្ត្រីមានសិទ្ធិស្មើគ្នាក្នុងការអប់រំ ក្នុងរឿងរ៉ាវទាំងអស់ទាក់ទងនឹង អាពាហ៍ពិពាហ៍ និងទំនាក់ទំនងគ្រួសារ ទទួលបាននូវព័ត៌មាន និងការគាំពារ សុខភាពស្មើគ្នា
- រក្សាខ្លួនអ្នកឱ្យដឹងពីព័ត៌មានអំពីច្បាប់ និងគោលនយោបាយនានា ដែលមានឥទ្ធិពលលើស្ត្រី និងសិទ្ធិរបស់ស្ត្រី
- ធ្វើយុទ្ធនាការឃោសនាផ្សព្វផ្សាយសិទ្ធិមនុស្សដែលបានធានាដោយអនុសញ្ញានេះ
- បញ្ចុះបញ្ចូលដើម្បីធ្វើឱ្យប្រាកដថារដ្ឋាភិបាលរបស់អ្នកសើរើពិនិត្យឡើងវិញ និងធ្វើឱ្យទាន់សម័យនូវការធ្វើច្បាប់ជាតិ ស្តីពីសិទ្ធិស្ត្រី ។

### ក្នុងនាមជាអង្គការមិនមែនរដ្ឋាភិបាល និងជាតំណាងសហគមន៍

- លើកស្ទួយ ការពារ និងធ្វើឱ្យបានសម្រេចសមភាព និងឱកាសរបស់ស្ត្រី
- សហការជាមួយរដ្ឋ ដើម្បីសម្រេចនូវគោលដៅនានានៃអនុញ្ញា

- តាមដានពិនិត្យការងាររបស់រដ្ឋ ហើយរាយការណ៍ឱ្យបានទៀងទាត់
- ពិនិត្យមើលលក្ខខណ្ឌនៃការធ្វើរបាយការណ៍ទៅស៊ី-ដ ដើម្បីធានាការ ប្រតិបត្តិតាមរបស់រដ្ឋាភិបាល
- ផ្តល់គំនិត និងឯកទេសជំនាញរបស់អ្នក ដើម្បីសម្រេចសិទ្ធិរបស់ស្ត្រី នៅគ្រប់ទិដ្ឋភាពនៃជីវិត
- ធ្វើការតស៊ូមតិ ដើម្បីអភិវឌ្ឍកម្មវិធីបណ្តុះបណ្តាល រៀបចំសម្រាប់អ្នកអនុវត្ត ដាក់ឱ្យប្រតិបត្តិ តាមនិងតាមដានច្បាប់ថ្មីៗ ។

## ក្នុងនាមជាសមាជិកនៃអង្គតុលាការ និងការអនុវត្តច្បាប់

- អនុវត្តច្បាប់ ដើម្បីការពារស្ត្រីពីអំពើហិង្សាដែលមានមូលដ្ឋានយេនឌ័រ និងធានាថាស្ត្រីមានភាពស្មើគ្នា ចំពោះមុខច្បាប់
- អនុវត្ត និងតាមដានច្បាប់ទាំងឡាយ ដើម្បីធានាការប្រតិបត្តិតាម
- ការពារនិងបម្រើ ជាអ្នកតស៊ូមតិ សម្រាប់អ្នកដែលត្រូវគេរំលោភសិទ្ធិ។

## ក្នុងនាមជារដ្ឋាភិបាល និងជាអ្នករ៉ាប់រងភារកិច្ច

- លើកស្ទួយ ការពារ និងធ្វើឱ្យបានសម្រេចសមភាព និងឱកាសរបស់ស្ត្រី
- បញ្ចូលតម្រូវការពិសេសៗរបស់ស្ត្រី ក្នុងការធ្វើផែនការ និងការអនុវត្តគោលនយោ-បាយ
- អនុម័តវិធានការបណ្តោះអាសន្នពិសេស ដើម្បីទូទាត់ភាពខុសគ្នារវាងស្ត្រី និងបុរសដែលរងការ រើសអើងពីអតីតកាល
- ចាត់ទុកធនធាន ដើម្បីផ្តល់មូលនិធិដល់គម្រោងពិសេសៗ សម្រាប់ស្ត្រីនៅតំបន់ជនបទ សម្រាប់ស្ត្រីក្រីក្រ ស្ត្រីជនជាតិដើម ឬស្ត្រីពិការ

- រៀបចំរបាយការណ៍ស្រមោលផ្តល់ព័ត៌មានជូនទៅគណៈកម្មការស៊ី-ដ អំពីស្ថានភាពបច្ចុប្បន្ននៃសិទ្ធិស្ត្រី នៅក្នុងប្រទេសរបស់អ្នក
- ធ្វើការងារ ដើម្បីធានាថាសិទ្ធិមនុស្សរបស់ស្ត្រី កាន់តែត្រូវបានការពារខ្លាំងឡើង នៅក្នុងរដ្ឋធម្មនុញ្ញរបស់អ្នក ដែលជាផ្នែកមួយនៃដំណើរការបច្ចុប្បន្ន នៃការកែទម្រង់រដ្ឋធម្មនុញ្ញ
- លើកកម្ពស់យុត្តិធម៌ សម្រាប់ស្ត្រី ផ្អែកលើមូលដ្ឋានសមភាពរវាងស្ត្រី និងបុរស (សមធម៌)
- បញ្ចុះបញ្ចូល ដើម្បីការអភិវឌ្ឍ និងការអនុវត្តកម្មវិធីព័ត៌មានសាធារណៈ ដែលបានច្នៃប្រឌិត ដើម្បីប្រាប់ព័ត៌មានដល់ស្ត្រីនិងកុមារ អំពីការប្រែប្រួលដែលមានក្នុងច្បាប់ ហើយប៉ះពាល់ និង មានឥទ្ធិពលដល់ការសម្រេចចិត្តរបស់គេ ។
- ធ្វើឱ្យសេវាមានគណនេយ្យភាព ចំពោះស្ត្រី និងបុរស ដែលជាអ្នកប្រើប្រាស់សេវាទាំងនោះ ។

# សទ្ទានុក្រម

## De Jure

Legitimate; lawful, as a matter of law having complied with all the requirements imposed by law. For example, a de jure government is the legal, legitimate government of a state and is so recognized by other states. In contrast, a de facto government is in actual possession of authority and control of the state.

## តាមនីតិន័យ តាមផ្លូវច្បាប់

តាមធម្មានុរូប ស្របច្បាប់ ក្នុងរឿងច្បាប់ គឺបានស្របទៅនឹង ការតម្រូវដែលច្បាប់បានដាក់បង្ខំ ។ ជាឧទាហរណ៍ រដ្ឋាភិបាល**តាមនីតិន័យ**មួយ គឺជារដ្ឋាភិបាលស្របច្បាប់ធម្មានុរូបនៃប្រទេសមួយ ហើយក៏មានការទទួលស្គាល់ពីប្រទេសដទៃៗទៀតដែរ ។ ផ្ទុយទៅវិញរដ្ឋាភិបាល **តាមព្រឹត្តន័យ** គឺស្ថិតនៅក្នុងការកាន់កាប់អំណាច និងត្រួតពិនិត្យរដ្ឋក្នុងស្ថានភាពពិតៗ ។

## De facto

"in fact" or "in practice" all that are found in the common experience as created or developed without or against a regulation. When discussing a legal situation, *de facto* designates illegitimate action of what happens in practice (which has substantially been established as unlawful). Also, may also be used when there is no relevant law or standard, but a common practice is well established, although perhaps not quite universal.

## តាមព្រឹត្តន័យ

"តាមពិត"ឬ"តាមប្រតិបត្តិ" អ្វីៗទាំងអស់ដែលគេមើលឃើញតាមបទពិសោធន៍សាមញ្ញ ដែលបង្កើត ឬអភិវឌ្ឍឡើងដោយគ្មាន ឬ ផ្ទុយនឹងនិយតប្បញ្ញត្តិ ។ ពេលយើងពិភាក្សាគ្នាអំពីស្ថានភាពក្នុងវិស័យច្បាប់ **តាមព្រឹត្តន័យ** សំដៅកំណត់នូវអំពើអធម្មានុរូប ចំពោះរបស់អ្វីដែលបានកើតឡើងនៅក្នុងការប្រតិបត្តិ (ដែលត្រូវបានធ្វើឱ្យឃើញឡើងច្រើនណាស់ដែរថា ខុសច្បាប់) ។ ម្យ៉ាងទៀត គេអាចប្រើ **តាម**

**ព្រឹត្តន័យ** នេះបាននៅពេលគ្មានច្បាប់ ឬបទដ្ឋានពាក់ព័ន្ធ ប៉ុន្តែមានការប្រតិបត្តិ ជាទូទៅមួយដែលកើតមានរឹងមាំរួចមកហើយ ទោះបីគ្មាន លក្ខណៈសាកល ណាស់ណាក្តី ។

## Gender:

Not to be confused with the biological differences between women and men and is determined at birth. Gender refers to the ROLES to the responsibilities of women and men that are created by social and cultural expectations about appropriate behavior and activities. These can change over time and vary within and around countries.

## យេនឌ័រ

សូមកុំច្រឡំជាមួយនឹង ភាពខុសគ្នាពីកំណើតផ្នែកជីវសាស្ត្រ រវាងបុរសនឹងស្ត្រីឡើយ ។ យេនឌ័រសំដៅដល់តួនាទី ការទទួលខុសត្រូវទាំងឡាយរបស់បុរសនិងស្ត្រី ដែលកើតឡើងពីការរំពឹងទុកនានា វិស័យសង្គម និងវប្បធម៌អំពី ឥរិយាបថ និងសកម្មភាពសមរម្យទាំងឡាយ ។ តួនាទីនិងការទទួលខុសត្រូវទាំងនេះអាចផ្លាស់ប្តូរក្នុងពេល ហើយប្រែប្រួលក្នុងនិងជុំវិញប្រទេសនានា ។

## Gender Mainstreaming

Making women's concerns and experiences as well as men's an integral part of the design, monitoring and implementation of all plans, policies, and programs.

## ការបញ្ជ្រាបយេនឌ័រ

ធ្វើឱ្យការយកចិត្តទុកដាក់និងបទពិសោធន៍របស់ស្ត្រី និងបុរស ទៅជាផ្នែកចាំបាច់នៃការរៀបចំ ការតាមដាន និងការអនុវត្តនូវផែនការគោលនយោបាយនិងកម្មវិធីទាំងអស់ ។

## Municipal/Domestic Law

It is domestic law that is applicable with in a nation. Although nationally it is referred to as a National law in

## ច្បាប់ជាតិ [ ក្រុង/ក្នុងស្រុក ]

គឺជាច្បាប់ក្នុងស្រុកដែលអនុវត្តនៅក្នុងប្រជាជាតិមួយ ។ ថ្វីបើក្នុងកម្រិតថ្នាក់ជាតិ

International law Parlance it is commonly referred to as Municipal Law

ច្បាប់នោះត្រូវបានយោងសេចក្ដីថាជាច្បាប់ជាតិក្នុងភាសាច្បាប់អន្តរជាតិក្ដីក៏ជាទូទៅគេហៅច្បាប់នេះថាជាច្បាប់ក្រុង ។

### NGO

Non-governmental organization

### អមរ

អង្គការមិនមែនរដ្ឋាភិបាល [មានហៅថាជា **អង្គការក្រៅរដ្ឋាភិបាលផងដែរ**]

### Negative Obligation

Negative obligation are those where the state does not have the right to encroach on the sphere of private liberties. In other words, these rights serve as protection for individuals against arbitrary exercise of state power. Right to freedom of conscience or expression is an example of Negative obligation.

### កាតព្វកិច្ចអវិជ្ជមាន

កាតព្វកិច្ចអវិជ្ជមានគឺជាកាតព្វកិច្ចទាំងឡាយណា ដែលរដ្ឋគ្មានសិទ្ធិរំលោភបំពានចូលក្នុងរង្វង់នៃឥស្សរភាពឯកជន ។ម្យ៉ាងវិញទៀតសិទ្ធិទាំងឡាយនេះ ជួយការពារឯកត្តជនទាំងឡាយ ទប់ទល់នឹងការប្រើប្រាស់អំណាចរដ្ឋតាមទំនើងចិត្ត ។ សិទ្ធិមានសេរីភាពខាងមនសិការ ឬការបញ្ចេញមតិ គឺជាឧទាហរណ៍មួយនៃការតព្វកិច្ចអវិជ្ជមាន។

### Positive Obligation

Positive obligation are those where the state is under obligation to guarantee certain basic needs. They are therefore rights concerned with the material, social and cultural welfare of the person which require resource investments. Right to an adequate standard of living for the health ad well-being of the person and

### កាតព្វកិច្ចវិជ្ជមាន

កាតព្វកិច្ចវិជ្ជមានគឺជាកាតព្វកិច្ចទាំងឡាយណាដែលរដ្ឋ មានកាតព្វកិច្ចធានាតម្រូវការជាមូលដ្ឋានមួយចំនួន ។ ដូច្នេះកាតព្វកិច្ចនោះគឺជាសិទ្ធិទាំងឡាយ ដែលពាក់ព័ន្ធនឹងវិស័យសម្ភារ សង្គម និង វប្បធម៌ នៃសុខុមាលភាពរបស់បុគ្គល ដែលតម្រូវឱ្យមានការវិនិយោគ

his/her family is an example of positive obligation.

ធនធាននានា ។ សិទ្ធិទទួលបានកម្រិត ជីវភាព គ្រប់គ្រាន់សម្រាប់ សុខភាព និង សុខវេទនី របស់បុគ្គល និង គ្រួសាររបស់គេ គឺជាឧទាហ-រណ៍មួយនៃកាតព្វកិច្ចវិជ្ជមាន ។

Concept

ទស្សនៈ

Vision

ទស្សនវិស័យ

# ការចូលរួមស្មើគ្នារបស់ ស្ត្រី និង បុរស តែងទទួលបានជោគជ័យ !




កម្មវិធីរបស់ UNIFEM

ឧបត្ថម្ភដោយ Canadian International Development Agency / Agence canadianne de développement international

រៀបចំដោយ

# កុមារី_កុមារា

## ត្រូវមានឱកាសស្មើគ្នាក្នុងការអប់រំ និងជ្រើសរើសមុខរបរទៅតាមការពេញចិត្ត !





កម្មវិធីរបស់ UNIFEM

ឧបត្ថម្ភដោយ Canadian International Development Agency / Agence canadienne de développement international

រៀបចំដោយ SILAKA

# ការចូលរួមការងារគ្រប់វិស័យរបស់ស្ត្រី
# គឺជាការលុបបំបាត់ការរើសអើង !




កម្មវិធីរបស់ UNIFEM

ឧបត្ថម្ភដោយ

Canadian International Development Agency

Agence canadienne de développement international

រៀបចំដោយ



# ផ្ដល់ឱកាសអោយ ស្ត្រី ចូលរួមក្នុងការងារសង្គម
# លុះត្រាតែបុរសជួយរំលែកការងារផ្ទះ !

កម្មវិធីរបស់ UNIFEM
ឧបត្ថម្ភដោយ Canadian International Development Agency
Agence canadienne de développement international
រៀបចំដោយ